ទស្សនាវដ្តី

ប្រជាជន

THE PRACHEACHUN MAGAZINE

ឆ្នាំទី២១ លេខ ២៤៣ ខែសីហា ឆ្នាំ ២០២១

និពន្ធនាយក :

លោក តាក សុនអ៊ី

គណៈកម្មការនិពន្ធ

១. លោក ខ្សៀវ ណារី

២. លោក អ៊ឹម សុន្ធរៈ

៣. លោក វង្ស សាវុធ

៤. លោក ទាវ សារៈមុនី

៥. លោក សុខ សុធន

លេខានិពន្ធ

១. លោក ស្វាយ ភីរុណ

២. លោក ម៉ក់ ឈិន

អ្នកបកប្រែភាសា

១. លោកស្រី ម៉ែន នារីសោភ័ត

អ្នកថតរូប

១. លោក សុផាត វីរៈមុនី

វិចិត្រករ

១. លោក ធា សាវុធ

អាស័យដ្ឋាន :

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ :

០២៣ ២១៩ ០៦៥

Address :

No 203 Preah

Norodom Bld.

Phnom Penh Cambodia

Tel : 023 219 065

សម្តេចតេជោ ហ៊ុន សែន ៖ កម្ពុជាប្រកាន់នយោបាយ ការបរទេសចម្រុះពណ៌, ជំនួយពីប្រទេសណា ក៏កម្ពុជាទទួលដែរ.....

៥

*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ជឿកនាំគណៈប្រតិភូជាន់ខ្ពស់សភាកម្ពុជា ចូលរួមមហាសន្និបាត.....*

៩

***សម្តេចក្រឡាហោម ស ខេង** ៖ ផ្តល់អនុសាសន៍ សំខាន់ៗមួយចំនួនសម្រាប់ការងាររដ្ឋបាល ថ្នាក់ក្រោមជាតិ.....*

១០

***សម្តេចពិជ័យសេនា ទៀ បាញ់** ៖ ជំនួយវ៉ាក់សាំង របស់ចិន រួមចំណែកប្រកបដោយប្រសិទ្ធភាព ក្នុងការទប់ស្កាត់ និងកាត់.....*

១១

*ឯកឧត្តម **គន់ គីម** ៖ សម្តេចតេជោ និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត តែងផ្សារភ្ជាប់ សុខទុក្ខជាមួយប្រជាជនជានិច្ច....*

១២

ក្រុមមុខ
យុទ្ធនាការចាក់វ៉ាក់សាំងបង្ការ
ជំងឺ COVID-19
ជូន កុមារ និងយុវវ័យ ដែលមានអាយុ ចាប់ពីអាយុ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ

មាតិកា
Contents

- *វិចារណកថា : គណបក្សប្រជាជនកម្ពុជា ជាកម្លាំងស្នូលតែមួយគត់ក្នុងការថែរក្សាការពាររដ្ឋធម្មនុញ្ញ..... ០១*
- *Editorial : The Cambodian People's Party - The Only Core Force in Upholding the Constitution..... 09*
- *អត្ថបទនយោបាយ: ប្រជាធិបតេយ្យ និងសិទ្ធិបញ្ចេញមតិត្រូវផ្សារភ្ជាប់គោលការណ៍នីតិរដ្ឋ..... ០៤*
- *សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ១៣*
- *សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ១៧*
- *សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច ១៩*
- *កម្ពុជាបន្តពុះពារសម្រេចឲ្យបាននូវចក្ខុវិស័យនៃការអភិវឌ្ឍរបស់ខ្លួន..... ២០*
- *អនុត្តរភាពទឹក: គម្រោងអាទិភាពចំនួន២៥ បាននិងកំពុងអនុវត្តតាមផែនការគ្រោងទុក..... ២១*
- *អត្ថបទវប្បធម៌: ប្រវត្តិ ខេត្តស្វាយរៀង..... ២៣*
- *ចំណេះដឹងទូទៅ: ព្យាករណ៍ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់អាស៊ីអាគ្នេយ៍..... ២៤*
- *ទឹកដីមាតុភូមិ: របរចម្លាក់ថ្ម បានធ្វើឲ្យមានការផ្លាស់ប្តូរជីវភាពប្រជាពលរដ្ឋនៅភ្នំជញ្ជាំង..... ២៥*
- *កំណាព្យ: បុណ្យ ភ្ជុំបិណ្ឌ.....សំណើច..... ២៨*

វិចារណកថា EDITORIAL

គណបក្សប្រជាជនកម្ពុជា ជាកម្លាំងស្នូលតែមួយគត់ ក្នុងការថែរក្សាការពាររដ្ឋធម្មនុញ្ញ

The Cambodian People's Party - The Only Core Force in Upholding the Constitution

*រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ ជាសមិទ្ធផលដ៏ឧត្តុង្គឧត្តម ថ្លៃថ្លាកើតចេញពីឆន្ទៈរួមរបស់ប្រជាជនកម្ពុជាមកពីគ្រប់និន្នាការនយោបាយ ដែលសម្តែងឡើងតាមរយៈការបោះឆ្នោតជាសកលក្រោយឆ្នាំ១៩៩៣ បាន និងកំពុងក្លាយជាមូលដ្ឋានគ្រឹះដ៏រឹងមាំ ធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាមាន សុខសន្តិភាពពេញលេញ មានការអភិវឌ្ឍ និងកាន់តែមានការរីកចម្រើន លូតលាស់នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងនីតិរដ្ឋ។ ប្រជាជនកម្ពុជា ទូទាំងប្រទេសដែលកំពុងរស់នៅក្រោមពន្លឺនៃសុខសន្តិភាព វិបុលភាព ភាពសុខដុមរមនា និងសុភមង្គលពេញលេញក្រោមម្លប់ដ៏ត្រជាក់របស់អង្គ-ព្រះមហាក្សត្រជាទីគោរពសក្ការៈ **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** និងក្រោមការដឹកនាំរបស់រាជ-រដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី សូមចូលរួមសម្តែងនូវក្តីអំណរសាទរយ៉ាងក្លៀវក្លា ក្នុង ឱកាសខួបទី២៨ ថ្ងៃបដិសន្ធិរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី២ (២៤ កញ្ញា ១៩៩៣- ២៤ កញ្ញា ២០២១) ។*

បច្ចុប្បន្ននេះ កម្ពុជាជាប្រទេសដែលមានឯករាជ្យ អធិបតេយ្យ និង បូរណភាពទឹកដីពេញលេញ មិនស្ថិតក្រោមការគៀបសង្កត់ មិនស្ថិតក្រោម ខ្សែញាក់របស់បរទេសណា ហើយប្រជាជនមានសិទ្ធិសេរីភាពពេញលេញ ក្នុងការអនុវត្តសិទ្ធិស្វ័យសម្រេចរបស់ខ្លួនចំពោះជោគវាសនានៃអនាគត របស់មាតុភូមិ។ ប៉ុន្តែមេរៀនពីអតីតកាលក្នុងពេលដែលកម្ពុជាធ្លាក់ទៅក្នុង គ្រោះមហន្តរាយ នៅតែស្ថិតក្នុងស្មារតីនៃការចងចាំរបស់ប្រជាជនកម្ពុជា គ្រប់ៗរូប និងគ្រប់ជំនាន់ មិនអាចរលុបទៅវិញបានឡើយ ។ មេរៀនទាំងនោះ ឆ្លុះបញ្ចាំងឲ្យឃើញច្បាស់ថា នៅពេលដែលប្រទេសមួយ បាត់បង់ឯករាជ្យ បាត់បង់អធិបតេយ្យ និងបូរណភាពទឹកដី ប្រជាជាតិនៃប្រទេសនោះនឹងត្រូវ ធ្លាក់ទៅក្នុងស្ថានភាពនៃគ្រោះរលត់រលាយដោយសារសង្គ្រាមរងនូវក្តីវិនាស ការនិរាសព្រាត់ប្រាស់ការបែកបាក់សាមគ្គីជាតិ និងត្រូវទទួលនូវការប្រមាថ មាក់ងាយពីពួកបរទេសដោយគ្មានទីបំផុត ។ ជាក់ស្តែងនៅពេលដែលពួក ក្បត់ជាតិ លន់នល់ សិរីមតៈ ឱនក្បាលធ្វើជាខ្ញុំកញ្ជះឲ្យពួកបរទេស ដោយ បំផ្លាញចោលឯករាជ្យអធិបតេយ្យជាតិ ធ្វើរដ្ឋប្រហារផ្តួលរំលំរបបរាជានិយម បំផ្លាញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី១ (ឆ្នាំ១៩៤៧-១៩៧០) មាតុភូមិកម្ពុជាក៏បានធ្លាក់ទៅក្នុងភ្នក់ភ្លើងសង្គ្រាមអស់រយៈពេល ៥ឆ្នាំ និង ១ខែ ក្នុងរបបសាធារណរដ្ឋខ្មែរ (ថ្ងៃ១៨ មីនា ឆ្នាំ១៩៧០-១៧ មេសា ឆ្នាំ១៩៧៥) និងរបបប្រល័យពូជសាសន៍ ប៉ុល ពត ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ (១៧ មេសា ឆ្នាំ១៩៧៥- ថ្ងៃ៦ មករា ឆ្នាំ១៩៧៩) ។ នៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដឹកនាំដោយគណបក្ស ប្រជាជនកម្ពុជា បានវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ សង្គ្រោះជាតិឲ្យ រស់ឡើងវិញ និងបើកឡើងនូវទំព័រថ្មីនៃប្រវត្តិសាស្ត្រ។ ពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩៣ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្រោយមកប្តូរជា

The Constitution, the supreme law of the nation, is a noble achievement born of the collective will of the Cambodian people from all political tendencies expressed through the post-1993 general elections and has become a solid foundation in ensuring the Kingdom of Cambodia's full peace, development, and increasingly prosperous, liberal, multi-party democracy and rule of law. Living in the light of peace, prosperity, harmony and complete happiness under the cool shadow of His Majesty King Norodom Sihamoni and the leadership of the Royal Government of Cambodia, led by Prime Minister Samdech Akka Moha Sena Padei Techo Hun Sen, Cambodians throughout the country express their heartfelt congratulations on the 28th anniversary occasion of the Constitution of the Second Kingdom of Cambodia (September 24, 1993 - September 24, 2021).

Today, Cambodia is an independent, sovereign, and with full territorial integrity, free from the oppression of any foreign country or wirepullers, whereas its people have the full right and freedom to exercise their right to self-determination for the future destiny of the motherland. The lessons of the past when Cambodia was plunged into a catastrophe, however, remain in the memory of every Cambodian and every generation. These lessons clearly show that when a country loses its independence, sovereignty and territorial integrity, that nation will fall into a state of catastrophe, war, destruction, disunity, and loss of national unity, henceforth, insulted by foreigners without end. When the traitors Lon Nol and Sarik Matak enslaved themselves to foreigners, while destroying the country's independence, national sovereignty, staging a coup to overthrow the monarchy, and destroying the Constitution of the First Kingdom of Cambodia (1947-1970), the Cambodian motherland fell into the flames of wars. It suffered five years and one month during the Khmer Republic (18 March 1970 – 17 April 1975), and three years, eight months and twenty days under the Pol Pot's genocidal regime (17 April 1975 – 6 January 1979). On January 7, 1979, the National United Front for Salvation of Kampuchea, led by the Cambodian People's Party, overthrew the genocidal regime, revived the nation and opened a new page in history. From 1979 to 1993, the government of the People's Republic of Kampuchea, later transformed into the State of Cambodian, led the

រដ្ឋកម្ពុជាបានដឹកនាំ ប្រទេសជាតិឆ្លងកាត់ឧបសគ្គរាប់ម៉ឺនរាប់សែនជំពូក និងបានស្វះស្វែងរកសុខសន្តិភាព និងការបង្រួបបង្រួមជាតិឡើងវិញ ។ អនុវត្តស្មារតីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសការបោះឆ្នោតសកលនៅខែឧសភា ឆ្នាំ១៩៩៣ បានដំណើរការ ហើយពេលនោះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី២ បានចាប់កំណើតឡើង ដែលនេះគឺជារដ្ឋធម្មនុញ្ញទី៦ ហើយរបស់កម្ពុជាបើគិតពីឆ្នាំ១៩៤៧មក។

ផ្អែកលើរដ្ឋធម្មនុញ្ញនេះ ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រកម្ពុជាដោយប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញមានប្រព័ន្ធនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។ ព្រះរាជាណាចក្រកម្ពុជា គឺជារដ្ឋឯករាជ្យ ឯកភាព មានអធិបតេយ្យភាព និងបូរណភាពដែនដីពេញលេញដែលមិនអាចរំលោភបំពានបាន ។ ប្រជាជនកម្ពុជាទូទាំងប្រទេសបានរួបរួមគ្នាប្រមូលផ្តុំអស់កម្លាំងកាយចិត្ត កម្លាំងបញ្ញាស្មារតីចូលរួមកសាងការពារជាតិប្រកបដោយភាពស្មាហាប់ អង់អាចឈានទៅមុខយ៉ាងឆាប់រហ័សនៅលើមាគ៌ាសន្តិភាព ប្រជាធិបតេយ្យ នីតិរដ្ឋ និងការអភិវឌ្ឍ ។ ជាមួយគ្នានេះ ដំណើរការបោះឆ្នោតជាបន្តបន្ទាប់តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យប្រព្រឹត្តទៅតាមការកំណត់នៃរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរួមមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចំនួន៦អាណត្តិ, ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បាន៤អាណត្តិ, ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌបាន ៣អាណត្តិ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបាន៤អាណត្តិ ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ នឹងប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ ២០២២ ខាងមុខ តាមការកំណត់នៃច្បាប់។

*ក្រោមពន្លឺនៃសន្តិភាព កម្ពុជាក៏មានឱកាសប្រឹងប្រែងងើបឈរដោយខ្លួនឯងប្រកបដោយមោទនភាពបំផុត កសាង និងអភិវឌ្ឍប្រទេសជាតិឡើងវិញ ធានាបាននូវបរិយាកាសអនុគ្រោះសម្រាប់លើកស្ទួយកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ។ ក្នុងអំឡុងពេលជាង ២ទសវត្សកន្លងទៅ កំណើនសេដ្ឋកិច្ចកម្ពុជាមានការកើនឡើងជុំវិញ៧% ជារៀងរាល់ឆ្នាំ។ កំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លារឹងមាំនេះបានធ្វើឲ្យកម្ពុជាបានទទួលឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ ២០១៥ ហើយអាចសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ប៉ុន្តែនៅឆ្នាំ ២០២០ ពិភពលោកទាំងមូល រួមទាំងប្រទេសកម្ពុជាយើងផងដែរ បានទទួលរងនូវវិបត្តិនៃការឆ្លងរាតត្បាតជំងឺកូវីដ-១៩ បង្កឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើសេដ្ឋកិច្ចសង្គម ដែលកម្ពុជាសម្រេចបានក្នុងរយៈពេល៣០ឆ្នាំចុងក្រោយ និងគំរាមកំហែងដល់ការអភិវឌ្ឍសម្រាប់រយៈពេលតទៅមុខទៀត ។ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់**សម្តេចតេជោ ហ៊ុន សែន** បានខិតខំពុះពារជំនះរាល់ការលំបាកនេះ ដែលរហូតមកដល់ពេលនេះ យើងនៅតែបន្តគ្រប់គ្រងបានការឆ្លងនៃជំងឺកូវីដ-១៩ និងផលវិបាករបស់វា ដោយការអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងដែលកំពុងប្រព្រឹត្តទៅទទួលបានលទ្ធផលខ្ពស់ បើធៀបជាមួយបណ្តាប្រទេសក្នុងតំបន់ និងក្នុងពិភពលោក រហូតទទួលបានការកោតសរសើរពីអង្គការសុខភាពពិភពលោក និងសហគមន៍អន្តរជាតិ។ ជាមួយលទ្ធផលនេះ កម្ពុជានឹងមានលទ្ធភាព ហើយកាន់តែមានសុទិដ្ឋិនិយមក្នុងការជំរុញដំណើរការសេដ្ឋកិច្ច សង្គម ឲ្យបន្តនិរន្តរភាពសម្រាប់ឆ្នាំ២០២១ នេះ និងបណ្តាឆ្នាំខាងមុខទៀត។ ក្នុងទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជា បាននិង*

country through tens of thousands of obstacles and sought peace and national reconciliation. Implementing the spirit of the Paris Agreement, the general elections of May 1993 took place and the Constitution of the Second Kingdom of Cambodia was born, the sixth Constitution of Cambodia since 1947.

Based on this Constitution, the Kingdom of Cambodia adheres to the Constitutional monarchy regime, with a liberal, democratic, multi-party political system and a market economy. The Kingdom of Cambodia is an independent, united, sovereign and complete territorial integrity that cannot be violated. The people of Cambodia all over the country have united physical and spiritual efforts to build a strong and courageous national defense and move forward rapidly on the path of peace, democracy, rule of law and development. At the same time, the elections in accordance with the principles of democracy proceeded with the provisions of the Constitution and the law, which includes the elections of the National Assembly for six terms, the elections of the Commune/Sangkat Councils for four terms, and the elections of the Capital-Provincial Councils, Municipal/District/Khan Councils for three terms. The country conducted four terms of the Senate elections. The fifth Commune/Sangkat Councils Elections will take place on June 5, 2022 as required by law.

In the light of peace, Cambodia has the opportunity to stand on its own with the greatest pride to rebuild and develop the nation, while ensuring a favorable environment for promoting economic growth, reducing poverty and improving people's livelihoods. Over the past two decades, Cambodia's economic growth has been around 7% annually. This strong economic growth has made Cambodia a low-middle-income country in 2015, with a prospect to become a high-middle-income country by 2030, and a high-income country by 2050. However, in 2020, the whole world, including Cambodia, suffered from the Covid-19 pandemic crisis, causing significant impacts on the socio-economic situation that Cambodia has achieved in the last 30 years and threatening development for the foreseeable future. However, the Royal Government of Cambodia, under the leadership of Samdech Techo Hun Sen, has worked hard to overcome these difficulties, and so far we have been able to control the spread of Covid-19 and its consequences by implementing an ongoing vaccination campaign and scoring a high result compared to other countries in the region and in the world. The World Health Organization and the international community have bestowed praises to such efforts and achievements. With this result, Cambodia will be able to and is even more optimistic, in promoting the sustainable socio-economic process for 2021 and the years to come.

In this regard, the Royal Government of Cambodia

កំពុងរៀបចំគ្រោងនឹងដាក់ចេញនូវផែនការស្តារសេដ្ឋកិច្ចឡើងវិញ ពីវិបត្តិកូវីដ-១៩ សម្រាប់ឆ្នាំ២០២១-២០២៣ ក្នុងគោលបំណង ***"អូសទាញកំណើនសេដ្ឋកិច្ចឲ្យត្រឡប់ទៅខិតជិតកំណើនសក្តានុពលប្រកបដោយចីរភាព និងបរិយាប័ន្តកម្ម តាមរយៈការធានារក្សានូវសន្តិភាព សន្តិសុខ ស្ថិរភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ លើគន្លងនៃប្រក្រតីភាពថ្មី ព្រមទាំងការលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចជាពិសេសមូលដ្ឋានឧស្សាហកម្មរឹងមាំ ដែលមានសមត្ថភាពនាំចេញខ្ពស់ និងផ្សារភ្ជាប់កាន់តែខ្លាំងក្លាជាមួយច្រវាក់ផ្គត់ផ្គង់តំបន់ និងពិភពលោក"។***

លើមូលដ្ឋាននេះ កម្ពុជានឹងផ្តល់អាទិភាពលើ ***១-****ការស្តារឡើងវិញដោយកសាងមូលដ្ឋានរឹងមាំសម្រាប់សេដ្ឋកិច្ចវិលទៅមាគ៌ានៃកំណើនឡើងវិញ* ***២-*** *បន្តដាក់ចេញវិធានការកែទម្រង់សំខាន់ៗ និង* ***៣-*** *ការកសាងភាពធន់ដោយពង្រឹងការត្រៀមខ្លួននិងការឆ្លើយតបទៅនឹងជំងឺឬស្ថានភាពស្រដៀងគ្នាដែលអាចផ្ទុះឡើងនាពេលអនាគត ។ តាមការព្យាករណ៍នៅឆ្នាំ២០២១ កំណើនសេដ្ឋកិច្ចកម្ពុជារំពឹងនឹងសម្រេចបាន ៤% ប៉ុន្តែអាស្រ័យដោយការបន្តឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ សេដ្ឋកិច្ច កម្ពុជាត្រូវបានប៉ាន់ស្មានថា នឹងមានកំណើន ២,៤% ។ ប៉ុន្តែទោះបីជួបគ្រោះហានិភ័យពីកត្តាខាងក្រៅប្រទេស និងបញ្ហាប្រឈមមួយចំនួននៅក្នុងប្រទេស ក៏រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញវិធានការមុតស្រួចនិងទាន់ពេលវេលា ដើម្បីបញ្ចៀស និងបន្ធូរបន្ថយសម្ពាធហានិភ័យ និងបញ្ហាប្រឈមនានាប្រកបដោយជោគជ័យ ។ យើងនៅតែមានសុទិដ្ឋិនិយមចំពោះអនាគតដ៏ត្រចះត្រចង់របស់ប្រទេសជាតិយើង ទោះបីជាត្រូវឆ្លងកាត់ឧបសគ្គ និងការលំបាកយ៉ាងណាក្តី សំខាន់បំផុតគឺការរួបរួមសាមគ្គីគ្នាជុំវិញរាជរដ្ឋាភិបាល ថែរក្សាការពារឲ្យបានគង់វង្សនូវរដ្ឋធម្មនុញ្ញ និងរបបរាជានិយមនៅកម្ពុជា ។*

ភាពស្ថិតស្ថេររឹងមាំនៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ២៨ឆ្នាំកន្លងមកនេះ ក៏បានឆ្លងកាត់នូវឧបសគ្គស្មុគស្មាញរាប់មិនអស់ អាស្រ័យជនក្បត់ជាតិ និងពួកអគតិព្យាយាមបំផ្លិចបំផ្លាញម្តងហើយម្តងទៀតមិនឈប់ឈរ។ ជាក់ស្តែងការកើតឡើងនូវព្រឹត្តិការណ៍ខែកក្កដា ឆ្នាំ១៩៩៧, ការប្រព្រឹត្តអំពើភេរវកម្មប្រដាប់អាវុធ ខែវិច្ឆិកា ឆ្នាំ២០០០, ការបង្កើតភាពអនាធិបតេយ្យ គ្រប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពិសេសព្រឹត្តិការណ៍បដិវត្តន៍ពណ៌ក្រោយការបោះឆ្នោតខែកក្កដា ឆ្នាំ២០១៣, ផែនការនៃការធ្វើរដ្ឋប្រហារតាមរយៈការវិលត្រឡប់មកវិញរបស់ពួកឧទ្ទាមនៅថ្ងៃទី៩ វិច្ឆិកា ឆ្នាំ២០១៩ ដោយបំផុសប្រជាជនឲ្យក្រោកឈរផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ និងឈានទៅផ្លាស់ប្តូររបបដឹកនាំរួមទាំងសកម្មភាពទុច្ចរិតជាច្រើនទៀត។

ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជា និងគណបក្សប្រជាជនកម្ពុជានៅតែប្រកាន់ខ្ជាប់គោលជំហរការពារដាច់ខាតរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងនៅតែជាកម្លាំងស្នូលតែមួយគត់ក្នុងការការពារព្រះរាជាណាចក្រកម្ពុជាឲ្យបានស្ថិតស្ថេរគង់វង្សក្នុងគ្រប់កាលៈទេសៈទាំងអស់ដោយមិនអនុញ្ញាតឲ្យកម្លាំងប្រតិកិរិយាណាមួយមកបំផ្លាញបានឡើយ ទោះជាត្រូវបង់ដោយតម្លៃណាក៏ដោយ៕

ទស្សនាវដ្តីប្រជាជន

has been preparing a plan for economic recovery from the Covid-19 crisis for 2021-2023 to "pull economic growth closer to sustainable and inclusive growth potential by maintaining peace, security, social stability and public order on the new normal trajectory. It will enhance competitiveness and promoting economic diversification, especially strong industrial bases with high export capacity and stronger linkages with regional and global supply chains." On this basis, Cambodia will give priority to (1) rehabilitation by building a strong foundation for the economy to return to the path of growth, (2) setting out key reform measures and (3) building resilience by strengthening readiness and response to a disease or similar conditions that may erupt in the future. Cambodia's economic growth for 2021 has been expected to realize at 4%, but due to the continued spread of Covid-19 owing to the February 20 community outbreak, the Cambodian economy is projected to grow by 2.4%. However, despite facing with the risk of external factors and some challenges in the country, the Royal Government of Cambodia has put in place sharp and timely measures to successfully avoid and mitigate the pressure, risks and challenges. We remain optimistic about the bright future of our nation, despite the obstacles and difficulties, but most importantly, the unity around the Royal Government to preserve the Constitution and the lasting monarchy in Cambodia.

The firmness and stability of the Constitution of the Kingdom of Cambodia over the past 28 years has also gone through countless complex obstacles due to the traitors and ill-intention people trying to destroy it times and again. Obviously noted, the occurrence of the July 1997 event, the acts of armed terrorism in November 2000, the creation of anarchy in every parliamentary elections, especially the color revolution after the July 2013 elections. They have plotted to stage a coup with the returning rebels on November 9, 2019, for which they inspired people to stand up and overthrow the legitimate government leading to regime change, and many other dishonest activities.

The Royal Government of Cambodia and the Cambodian People's Party, however, still adhere to the position of absolute protection of the Constitution of the Kingdom of Cambodia and remain the only core force in defending the lasting Kingdom of Cambodia in all circumstances, and at whatever cost it may take, allowing no destruction to occur by any reactionary forces./.

THE PRACHEACHUN MAGAZINE

សម្តេចតេជោ ហ៊ុន សែន ៖ សូមបងប្អូនជនរួមជាតិនៅបន្តរក្សា និងអនុវត្តគោលការណ៍បង្ការ ទប់ស្កាត់ និងវិធានសុខាភិបាល «៣ការពារ ៣កុំ» ឲ្យបានខ្ជាប់ខ្ជួន កុំឆ្វេសប្រហែស

ប្រជាធិបតេយ្យ និងសិទ្ធិបញ្ចេញមតិត្រូវផ្សារភ្ជាប់គោលការណ៍នីតិរដ្ឋ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ច្បាស់ថា ប្រទេសកម្ពុជាបានប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស ។ ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងភាពរីយកិច្ចដូចគ្នា ទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិឋានៈសង្គមធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។ ប្រជាពលរដ្ឋមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។

រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់**សម្តេចតេជោ ហ៊ុន សែន** បានជំរុញ និងលើកទឹកចិត្តយ៉ាងខ្លាំងក្លាក្នុងការអនុវត្តប្រជាធិបតេយ្យនៅកម្ពុជា ដែលរហូតមកដល់សព្វថ្ងៃកាន់តែមានជំហានលូតលាស់គួរឲ្យកត់សម្គាល់។ ប្រជាពលរដ្ឋបានប្រើប្រាស់សិទ្ធិរបស់ខ្លួនក្រោមក្របខណ្ឌច្បាប់ចូលរួមបំពេញភារកិច្ចជូនសង្គមជាតិដែលមិនត្រឹមតែបានរួមចំណែកលើកកម្ពស់ប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែបានជួយដល់ការអភិវឌ្ឍប្រទេសឲ្យមានការរីកចម្រើនយ៉ាងខ្លាំង។

ជាមួយនឹងការជំរុញការអនុវត្តលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិសេរីភាពនេះ ការពង្រឹងការអនុវត្តគោលការណ៍នីតិរដ្ឋក៏ត្រូវបានប្រកាន់យកយ៉ាងមឺងម៉ាត់ដោយមិនអនុញ្ញាតឲ្យជនណាមួយ ក្រុមណាមួយឆ្លៀតទៅជ្រកក្រោមផ្លាកប្រជាធិបតេយ្យធ្វើសកម្មភាព អានាធិបតេយ្យបំផ្លិចបំផ្លាញប្រទេសជាតិបំផ្លាញដំណើរការប្រជាធិបតេយ្យនៅកម្ពុជាបានឡើយ។ ពួកប្រឆាំង និងមជ្ឈដ្ឋានអគតិ តែងតែឃោសនាបំភាន់អំពីការអនុវត្តលទ្ធិប្រជាធិបតេយ្យ ដោយគេមិនដែលនិយាយ ឬធ្វើជាបំភ្លេច មិននិយាយអំពីគោលការណ៍នីតិរដ្ឋ ដែលជាធាតុផ្សំមិនអាចខ្វះបានក្នុងដំណើរការនៃប្រជាធិបតេយ្យនៅក្នុងសង្គមជាតិ ។ហេតុអ្វី? ព្រោះថា បើពួកនេះហ៊ាននិយាយអំពីនីតិរដ្ឋក្នុងសង្គមប្រជាធិបតេយ្យ ពួកគេនឹងមិនអាចប្រព្រឹត្តអំពើអាណាធិបតេយ្យបានឡើយដូចជាការបំផុសបំផុលញុះញង់ប៉ុនប៉ងបង្កើតឲ្យមានអំពើចលាចលក្នុងសង្គម ការបំផុសឲ្យមានការរើសអើងជាតិសាសន៍ ការប្រមូលកម្លាំងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ប្រមាថ ព្រះមហាក្សត្រ និងបញ្ហាព្រំដែនជាដើម។ នេះមិនមែនជាសកម្មភាពនៃការបញ្ចេញមតិស្របតាមច្បាប់ដែលបានកំណត់ឡើយ ប៉ុន្តែគឺជាការរំលោភបំពានច្បាប់យ៉ាងធ្ងន់ធ្ងរបំផុតដែលគ្រប់ប្រទេសប្រកាន់យករបបប្រជាធិបតេយ្យត្រឹមត្រូវមិនអនុញ្ញាតជាដាច់ខាត។ នៅប្រទេសប្រជាធិបតេយ្យធំៗលើពិភពលោកនេះ សុទ្ធតែអនុវត្តយ៉ាងមឺងម៉ាត់បំផុតចំពោះជនល្មើសច្បាប់ដែលជ្រកក្រោមផ្លាកប្រជាធិបតេយ្យហើយធ្វើសកម្មភាពបំពានច្បាប់ដោយបានយកជនទាំងនោះឲ្យទៅទទួលខុសត្រូវចំពោះមុខច្បាប់ដោយមិនមានការលើកលែង។

នៅកម្ពុជាក៏ដូចគ្នា។ កន្លងទៅនេះក៏មានករណីជនប្រព្រឹត្តល្មើសច្បាប់មួយចំនួនត្រូវបានសមត្ថកិច្ចចាប់បញ្ជូនខ្លួនទៅកាន់តុលាការដើម្បីផ្តន្ទាទោស។ ជនទាំងនេះបានបំពានទៅលើសិទ្ធិនៃការបញ្ចេញមតិប៉ុនប៉ងធ្វើឲ្យលទ្ធិប្រជាធិបតេយ្យដើរខុសគន្លង តាមរយៈការប្រព្រឹត្តអំពើអនាធិបតេយ្យជាច្រើន ដែលសកម្មភាពខ្លះជាអំពើក្បត់ជាតិទៀតផង។ ជាក់ស្តែងថ្មីៗនេះ តុលាការបានធ្វើការផ្តន្ទាទោសបុគ្គលដែលរំលោភច្បាប់ធ្វើអត្ថាធិប្បាយលើបញ្ហាព្រំដែនដោយប្រើប្រាស់ព័ត៌មានបំភ្លៃ និងបំផ្លើសការពិត ដែលនោះពុំមែនជាការអនុវត្តសេរីភាពនៃការបញ្ចេញមតិទេ ប៉ុន្តែជាការជុតបញ្ឆេះឲ្យមានការកើតឡើងនូវទស្សនៈជាតិនិយមជ្រុល ហើយសាលក្រមនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីការពង្រឹងគោលការណ៍ នីតិរដ្ឋយ៉ាងមឺងម៉ាត់ក្នុងដំណើរការនៃការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ រដ្ឋធម្មនុញ្ញកម្ពុជាការពារសេរីភាពក្នុងការបញ្ចេញមតិស្របច្បាប់ប៉ុន្តែមិនមែនសេរីភាពក្នុងការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ បង្ខូចកេរ្តិ៍ឈ្មោះ ញុះញង់ឲ្យមានអំពើហិង្សា និងសាបព្រោះការរើសអើងជាតិសាសន៍ឡើយ។ ការអនុវត្តនូវសិទ្ធិសេរីភាពនៃការបញ្ចេញមតិត្រូវភ្ជាប់ទៅនឹងករណីកិច្ច និងការទទួលខុសត្រូវក្នុងក្របខណ្ឌច្បាប់។ ប៉ុន្តែអ្វីដែលគួរឲ្យសោកស្តាយនៅពេលដែលតុលាការផ្តន្ទាទោសពួកទាំងនេះបែរជាមានជនបរទេសខ្លះ អង្គការក្រៅរដ្ឋាភិបាលខ្លះប្រតិកម្មទាំងទទឹងទិស ធ្វើជាមិនយល់ឬមិនយល់ទាល់តែសោះអំពីការអនុវត្តវិធានការច្បាប់របស់កម្ពុជា។ ពួកគេថែមទាំងបានបញ្ចេញប្រតិកម្មមានលក្ខណៈជាការជ្រៀតជ្រែកលើការងាររបស់ស្ថាប័នតុលាការតាមរយៈការបង្គាប់បញ្ជា ការរិះគន់ដោយគ្មានហេតុផល និងបង្ហាញនូវភាពលំអៀងរបស់ខ្លួនទៅរកជនប្រព្រឹត្តអំពើល្មើសច្បាប់ដោយគ្មានការខ្មាស់អៀនសូម្បីតែបន្តិច។

កម្ពុជានៅតែប្រកាន់យ៉ាងខ្ជាប់ខ្លួនការអនុវត្ត និងការលើកកម្ពស់ប្រជាធិបតេយ្យ សេរីពហុបក្ស ការលើកស្ទួយសិទ្ធិសេរីភាព និងនីតិរដ្ឋឲ្យមានជំហានលូតលាស់ទៅមុខទៀត លើមូលដ្ឋានរក្សាឲ្យបាននូវសន្តិភាព និងស្ថិរភាពនយោបាយព្រមទាំងការអភិវឌ្ឍប្រកបដោយចីរភាព៕

សម្តេចតេជោ ហ៊ុន សែន ៖ កម្ពុជាប្រកាន់នយោបាយការបរទេសចម្រុះពណ៌, ជំនួយពីប្រទេសណាក៏កម្ពុជាទទួលដែរ

❋ សម្តេចតេជោ ហ៊ុន សែន លើកបញ្ហាក់ពីកត្តាចំនួន៥ ដែលនាំឲ្យការចាក់វ៉ាក់សាំងទទួលជោគជ័យនៅកម្ពុជា

❋ នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០២១ **សម្តេច-អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ១៩ ដល់កុមារ និងយុវវ័យដែលមានអាយុចាប់ពី ១២ឆ្នាំដល់ក្រោម ១៨ឆ្នាំ នៅវិមានសន្តិភាព។

សម្តេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសបើកយុទ្ធនាការចាក់វ៉ាក់សាំង កូវីដ១៩ ដល់កុមារ និងយុវវ័យដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៨ឆ្នាំ

ក្នុងឱកាសនោះ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា ប្រជាពលរដ្ឋ ដែលបានចាក់វ៉ាក់សាំងប្រភេទ Sinopharm និង Sinovac រួចហើយត្រូវចាក់ AstraZeneca ជាដូសទី៣ ដែលជាដូសជំរុញ ។ ចំពោះប្រជាពលរដ្ឋកម្ពុជា ដែលចាក់វ៉ាក់សាំងអាស្ត្រា-ហ្សេនេកា ត្រូវចាក់ដូស ទី៣ ដោយប្រើវ៉ាក់សាំងស៊ីណូវ៉ាក់។ ប៉ុន្តែការចាក់ដូសទី៣ នេះ ត្រូវផ្តោតទៅលើក្រុមជួរមុខដែលមានប្រមាណ ៥០ម៉ឺនទៅ១លាននាក់សិន ឯពលរដ្ឋនឹងចាក់តាមក្រោយ។ ។ សម្តេចចង់បានការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ លើកុមារក្រោមអាយុ១២ឆ្នាំបន្តទៀត ដើម្បីបង្កើតប្រព័ន្ធភាពស៊ាំចំពោះកុមារក្នុងការទប់ស្កាត់ ជំងឺកូវីដ១៩ នៅក្នុងប្រទេស តែត្រូវរង់ចាំមានការអនុម័តឬទទួលស្គាល់ពីអង្គការសុខភាពពិភពលោក(WHO) សិន ។ **សម្តេចតេជោ ហ៊ុន សែន** បានផ្តល់យោបល់ទៅលោកជំទាវ **ឱ ឥណ្ណឌីន** ឱ្យបញ្ជូនវ៉ាក់សាំង Johnson&Johnson ដែលជាជំនួយរបស់រដ្ឋាភិបាលអាមេរិកទៅចាក់ជូនប្រជាពលរដ្ឋជនជាតិដើមភាគ-តិច នៅតំបន់ភាគល្អាសាននៃប្រទេសកម្ពុជាដូចជា ខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង និងព្រះវិហារ ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ក្នុងដំណាក់កាលនៃការរាតត្បាតកូវីដ១៩ រយៈពេលជាង ១ឆ្នាំមកនេះ កម្ពុជាពិតជាបានចំណាយយ៉ាងធំ មិនត្រឹមតែចំណាយលើកូវីដ១៩ ប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវចំណាយទៅលើទឹកជំនន់ថែមទៀត។ ការចំណាយពេលនេះគឺអាចសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គបានប្រមាណ១០ ស្ពាន ។ សម្តេចតេជោក៏បានថ្លែងប្រាប់ ពីប្រភពថវិកាជួយទ្រទ្រង់ដល់ការចំណាយរបស់រាជរដ្ឋាភិបាលក្នុងបរិបទកូវីដ១៩ នាពេលកន្លងមកនេះបានមកពី ៥ប្រភពផ្សេងគ្នា គឺ **ប្រភពទី១**-បានមកពីចំណូលចរន្តក្នុង១ខែ ជាមធ្យមមានចំនួនជាង ៤០០លានដុល្លារ។រយៈពេល៧ខែឆ្នាំ២០២១ ចំណូលគយនិងពន្ធដារទទួលបានចំនួន ៣.០៦១ លានដុល្លារអាមេរិក ដែលក្នុងនោះបានពីពន្ធដារចំនួន១.៧១៦លានដុល្លារស្មើប្រមាណជាង៧៦,៦%,ចំណូលពន្ធគយបាន ១.៣៤៥ លានដុល្លារស្មើនឹង៥៦.០៩% ។ នៅសល់៥ខែទៀតសង្ឃឹមថា យ៉ាងហោចណាស់បាន ២ពាន់លានដុល្លារបន្ថែមទៀត ។ យើងមិនមែនប្រយុទ្ធប្រឆាំងតែទៅលើកូវីដ១៩នោះទេ គឺយើងនៅបានស្ពារហេដ្ឋារចនាសម្ព័ន្ធចំណាយអស់រាប់រយលានដុល្លារនៅក្រុងព្រះសីហនុ និងសាងសង់ផ្លូវ៣៨ខ្សែ នៅខេត្តសៀមរាប ការតបណ្តាញអគ្គិសនីរួមទាំងវិនិយោគផ្នាល់ទាំងថវិកាបដិភាគផ្លូវក្រវាត់ក្រុងទី៣ ។ យើងមិនបានស្នើសុំទៅប្រទេសម្ចាស់ជំនួយម្ចាស់កម្ចីដើម្បីផ្អាកការសងទេ គឺយើងនៅតែបន្តសងគេដដែល។ រាជរដ្ឋាភិបាលក៏បានចំណាយទៅលើប្រាក់ខែមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធមួយខែប្រមាណ ២៥០ លានដុល្លារ នៅសល់ជាង ១០០ លានដុល្លារទៀត សម្រាប់ចាយទៅលើបញ្ហាផ្សេងៗ។ **ប្រភពទី២**-រាជរដ្ឋាភិបាលបានសន្សំសាច់ប្រាក់បានជាង ៣ ពាន់លានដុល្លារមុនកូវីដ១៩ ។ មកដល់ពេលនេះយើងបានចាយអស់ជាង១ពាន់លានដុល្លារ។យើងនៅសល់សាច់ប្រាក់ប្រមាណជាង ២ពាន់លានដុល្លារ ដោយមិនរាប់ពីទុនបំរុងអន្តរជាតិប្រមាណជា ២០ ពាន់លានដុល្លារ និងមាសប៉ុន្មានសិបតោននោះទេ។ យើងចាយសម្រាប់ជួយដល់ប្រជាពលរដ្ឋជិត ៣លាននាក់ ដែលត្រូវចិញ្ចឹមមានរយៈពេល ១០ខែ អស់ជាង ៤០០ លានដុល្លារ ។ កម្មករដែលបាត់បង់ការងារទាំងនៅក្នុងរោងចក្រឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ប៉ុន្មានម៉ឺននាក់ទៀតដែលយើងត្រូវផ្តល់ប្រាក់ ជួយចិញ្ចឹមគាត់ អត់ធ្វើការ ប៉ុន្តែគាត់បានប្រាក់ពីថៅកែ៣០ដុល្លារនិងពីរដ្ឋ៤០ដុល្លារ។ផ្នែកទេសចរណ៍ម្នាក់ទទួលបាន ៤០ដុល្លារ ។ យើងបានទម្លាក់សាច់ប្រាក់ពលកម្មទៅកាន់ជនបទដែលអាចផ្តល់ការងារឲ្យគាត់ធ្វើ ជីកព្រែកប្រឡាយលើកទំនប់ គាត់អាចទទួលបានចំណូលនោះបន្ថែមទៀត។ នេះជាការគិតគូររបស់យើង ហើយនេះមិនគ្រាន់តែប្រកាសឲ្យល្អមើលទេគឺប្រជាជនបានទទួល

លុយពិតប្រាកដ។ **សម្តេចតេជោ ហ៊ុន សែន** បន្តថា រាជរដ្ឋាភិបាលបានចំណាយគ្រាន់តែចិញ្ចឹមអ្នកធ្វើចត្តាឡីស័កកន្លងទៅអស់ជិត ៧ ពាន់លានរៀល គឺជិត ២ លានដុល្លារ ដោយមិនគិតទៅដល់អ្នកព្យាបាលក្នុងមន្ទីរពេទ្យរាប់ម៉ឺននាក់ ទាំងនៅព្រំដែន ទាំងនៅទីក្រុងភ្នំពេញ និងបណ្តាខេត្ត។ យើងមិនដែលឲ្យប្រជាជនណាម្នាក់ដេកស្លាប់តាមចិញ្ចើមផ្លូវនោះទេ។ ប្រទេសដទៃមាន ប៉ុន្តែកម្ពុជាមិនមានទេ ។ ខ្ញុំនៅតែរក្សាចិញ្ចឹមគំនិតថាបើហោចបំផុតក៏មាន ក្តាមឈូសមួយជូនពលរដ្ឋ ដោយមិនអនុញ្ញាតឲ្យខ្វះក្តាមឈូស ហើយយកសពទៅកប់ដោយរុំកន្ទេល រុំនឹងក្រណាត់កៅស៊ូនោះទេ។ **ប្រភពទី៣៖** កន្លងទៅ យើងមានព្រះមហាក្សត្រ យើងមានហ្លួងម៉ែ យើងមានសប្បុរសជនដែលស្ម័គ្រចិត្តចូលរួមថវិកាប្រឆាំងកូវីដ និងគ្រោះទឹកជំនន់ដែលមកដល់ពេលនេះលុយដែលសប្បុរសជនបានជួយទាំងអស់ជាង ១៤០ លានដុល្លារ។ នេះជាការចូលរួមមួយដ៏ធំនៃចលនាជាតិ បើគ្មានសាមគ្គីភាពជុំវិញរាជរដ្ឋាភិបាលទេ គឺគ្មានអ្នកណាចូលរួមទេ។ **ប្រភពទី៤៖** យើងក៏មានការគាំទ្រពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិផងដែរ។ ជំនួយរបស់យើងពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដែលយើងបានចាយក្នុងរយៈពេលកន្លងទៅនេះមាន ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ធនាគារពិភពលោក និងធនាគារអឺរ៉ុប ដែលនេះជាផ្នែកសម្រាប់ការប្រយុទ្ធប្រឆាំងកូវីដ១៩។ យើងត្រូវដោះស្រាយបញ្ហាសេដ្ឋកិច្ចផងដែរ ដូចជាធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ឲ្យយើងចំនួន ៩៥ លានដុល្លារអាមេរិក ដើម្បីទិញវ៉ាក់សាំងយើងមិនទាន់បានប្រើទេ សម្រាប់យើងត្រូវការប្រើនៅពេលដែលយើងទិញវ៉ាក់សាំងបន្ថែមសម្រាប់ដូសទី៣។ **ប្រភពទី៥៖** យើងក៏មានជំនួយទ្វេភាគីពីប្រទេសមិត្តភ័ក្ត្រមួយចំនួន ដូចជាប្រទេសចិនផ្តល់ជាសម្ភារៈពេទ្យរួមជាមួយវ៉ាក់សាំង,ប្រទេសជប៉ុនផ្តល់ជារថយន្តដឹកអ្នកជំងឺជាថ្នាំពេទ្យផ្តល់ជាសម្ភារៈបរិក្ខារសម្រាប់ការប្រយុទ្ធប្រឆាំងជាមួយកូវីដ១៩ រាប់ទាំងវ៉ាក់សាំងបានមកដល់ និងត្រៀមមកដល់។ ប្រទេសអាមេរិកបានប្រកាសផ្តល់ ១១លានដុល្លារនិងវ៉ាក់សាំងជាង១លានដូស, អង់គ្លេសជិតមកដល់, អូស្ត្រាលីទោះបីមិនទាន់មកដល់ក៏បានប្តេជ្ញាចិត្តជាមួយនឹងការផ្តល់ឲ្យកម្ពុជា, ប្រទេសជិតខាងយើងទាំងវៀតណាមទាំងថៃក៏បានផ្តល់ឱ្យយើង ហើយវៀតណាមក៏បានជួយយើងច្រើនដែរនៅតាមខេត្តជាប់ព្រំដែនក៏ដូចជាកងទ័ព។ យើងក៏បានចែករំលែកទៅប្រទេសនានាខ្លះដែរតាមលទ្ធភាពដែលអាចធ្វើទៅរួចថ្មីៗបានជួយទៅវៀតណាម ជួយទៅឡាវ ជួយទៅមីយ៉ាន់ម៉ា ជួយទៅនេប៉ាល់ និងជួយទៅបង់ក្លាដេសផងដែរ ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កំណើនសេដ្ឋកិច្ចរបស់កម្ពុជាដំបូងឡើយព្យាការណ៍ថានឹងមានកំណើន៤,១%នៅឆ្នាំ២០២១ ប៉ុន្តែការរំខានរបស់ជំងឺកូវីដ១៩ យើងព្យាករណ៍សេដ្ឋកិច្ចមកនៅត្រឹមតែ ២,៥%ប៉ុណ្ណោះ។ ក្នុងអំឡុងពេលជួបវិបត្តិនៃជំងឺកូវីដ១៩ សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកខ្លាំងទៅលើវិស័យកសិកម្ម។ ទោះបីកម្ពុជាជួបវិបត្តិនេះក្តីតែកម្ពុជាមិនបាត់បង់ពីការខ្វះខាតស្បៀងនោះទេ។ការនាំចេញផលិតផលកសិកម្មនៅរយៈពេលប៉ុន្មានខែដើមឆ្នាំនេះមានការកើនឡើងលើសការរំពឹងទុក ថ្វីត្បិតតែការនាំចេញអង្ករមានការធ្លាក់ចុះបន្តិច ប៉ុន្តែការនាំចេញស្រូវទៅកាន់ប្រទេសវៀតណាម និងទៅកាន់ប្រទេសអារ៉ាប់រួមមានកំណើនរហូតដល់២០០% ។ ការនាំចេញគ្រាប់ស្វាយចន្ទីកើនឡើងជិត៣០០% ការនាំចេញស្វាយ ចេក ដែលសរុបនៃការនាំចេញទាំងអស់មានទំហំទឹកប្រាក់រាប់ពាន់លានដុល្លារ។ ក្រៅពីវិស័យកសិកម្មយើងមើលឃើញវិស័យឧស្សាហកម្មធុនតូច និងមធ្យមនៅតែជាចំណុចស្នូលក្នុងកំណើនសេដ្ឋកិច្ចដែលទាមទារឲ្យរកវិធីក្នុងការជំរុញកំណើន។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាឱ្យសមត្ថកិច្ចអនុវត្តច្បាប់យ៉ាងម៉ឺងម៉ាត់បំផុត ចំពោះអ្នកផ្តើននឹងវិធានការការពារកូវីដ១៩ ដោយមិនអាចទុកឱ្យមនុស្ស១ ឬ២នាក់ បំផ្លាញមនុស្សរាប់ពាន់ រាប់ម៉ឺន ឬរាប់សែន លាននាក់នោះទេ។ សម្តេចតេជោថា៖ «ចំពោះអ្នកមើលស្រាលមិនស្តាប់បង្គាប់ មិនគោរពតាមវិធានសុខាភិបាល យើងទើបនឹងបង្កើតនូវអនុគណៈកម្មការដឹកនាំអនុវត្តច្បាប់ ។ ច្បាប់របស់យើងមានសម្រាប់ដាក់ទោសទណ្ឌ។ សម្តេចតេជោ បានសង្កត់ធ្ងន់ថា ប្រសិនបើគោរពសិទ្ធិបុគ្គលដែលផ្តើននឹងវិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ម្នាក់ហើយទុកឱ្យប្រជាជនរងគ្រោះជាច្រើននាក់នោះគឺមិនបានទេ។ ត្រង់ចំណុចនេះដែរ ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជាក៏បានចោទសួរទៅក្រុមអ្នកសិទ្ធិមនុស្សមួយចំនួនតូចថា ត្រូវយល់ឱ្យច្បាស់ចំពោះបញ្ហាដែលជនទាំងនោះបង្កឡើង និងសូមកុំរិះគន់វាយប្រហាររដ្ឋាភិបាលព្រមទាំងមន្ត្រីអនុវត្តច្បាប់ដើម្បីយកតែបុងឱ្យសោះ។សម្តេចតេជោបានប្រដៅទៅក្រុមអ្នកសិទ្ធិមនុស្សនិយមថា សូមកុំគិតតែ សិទ្ធិលើបុគ្គលម្នាក់ប៉ុន្តែបែរជាមិនបានគិតទៅលើសិទ្ធិមនុស្សរាប់ម៉ឺននាក់។ ដូច្នេះការបង្កើតឡើងនូវអនុគណៈកម្មការដឹកនាំនិងអនុវត្តច្បាប់ គឺមានគោលដៅរួម ដើម្បីជាកពិន័យទៅលើជនដែលបំពានច្បាប់។ ដោយសារតែមានបុគ្គលមួយចំនួនមិនរាងចាល បន្តធ្វើនល្មើសវិធានការការពារជំងឺកូវីដ១៩ បំពាននឹងច្បាប់ ដូច្នេះជនទាំងនោះត្រូវតែចាប់បញ្ជូនទៅពន្ធនាគារ។

សម្តេចតេជោ ហ៊ុន សែន បានប្រកាសហាមមន្ទីរពេទ្យរដ្ឋនៅទូទាំងប្រទេសមិនឱ្យយកប្រាក់ពីប្រជាពលរដ្ឋដែលទៅធ្វើតេស្តរកមេរោគកូវីដ-១៩ ជាដាច់ខាត ក៏ដូចជាបានស្នើទៅកាន់មន្ទីរពេទ្យឯកជនទាំងឡាយសូមកុំឱ្យយកថ្លៃធ្វើតេស្តខ្ពស់ពេក ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងការីករាលដាលមេរោគកូវីដនេះបានទាន់ពេលវេលា។ ការធ្វើតេស្ត គឺពិតជាមានសារសំខាន់ខ្លាំងណាស់ ដើម្បីគ្រប់គ្រងបានទាន់ពេលវេលា ហើយកន្លងទៅនេះ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យវិស័យ ឯកជននាំចូលឧបករណ៍ធ្វើតេស្ត ប៉ុន្តែប្រជាជនក្រីក្រពុំមានលទ្ធភាព បង់ប្រាក់ថ្លៃធ្វើតេស្តឡើយ ដូច្នេះបញ្ហានេះរដ្ឋនៅបន្តទទួលខុសត្រូវ។ សម្តេចតេជោ ស្នើឱ្យក្រសួងសុខាភិបាលចែករំលែកនូវឧបករណ៍ធ្វើតេស្តទៅកាន់បណ្តាមន្ទីរពេទ្យដែលនៅទីកន្លែងឆ្ងាយៗ និងចាំបាច់ក្នុងការធ្វើតេស្តជូនប្រជាពលរដ្ឋ។ សម្តេចតេជោបានបន្តថា នៅលើពិភពលោកនេះមានប្រទេសមិនច្រើនទេ ដែលធ្វើតេស្តក៏អត់អស់លុយ រាប់ទាំងព្យាបាលក៏អត់អស់លុយ។ ជនបរទេសចាក់វ៉ាក់សាំងនៅកម្ពុជាក៏អត់អស់លុយមួយសេន ។ **«ខ្មែរក្រ តែខ្មែរមានទឹកចិត្ត»** ខណៈនៅប្រទេសក្នុងតំបន់ធ្វើតេស្តត្រូវបង់លុយ ។ សម្តេចតេជោបានថ្លែងថា **«សម្រាប់ការធ្វើតេស្តដោយគ្រូពេទ្យរបស់ រដ្ឋដាច់ខាតអត់យកប្រាក់ សូមបញ្ជូនសារនេះឱ្យដល់ប្រជាពលរដ្ឋ»។** សម្តេចតេជោថ្លែងថា ចំពោះការធ្វើតេស្តនេះត្រូវបែងចែកជា២៖ **ផ្នែករដ្ឋ** ដាច់ខាតមួយសេនក៏មិនឱ្យយកប្រាក់ពីប្រជាពលរដ្ឋ មិនថាអ្នកមាន មិនថាអ្នកក្រ។ ប្រសិនបើយកប្រាក់ពីអ្នកជំងឺក៏មិនអាចឱ្យកម្ពុជាក្លាយជាអ្នកមានបានដែរ ។ យើងចាយដល់ទៅពាន់លានបាត់ទៅហើយ ឬក៏រាប់រយលានដុល្លារ

បាត់ទៅ ហើយយើងបន្តចាយបន្តិចទៅទៀតក៏វាមិនដួលរលំសេដ្ឋកិច្ចកម្ពុជាដោយសារការធ្វើតេស្តហ្នឹងទេ។ ឯចំពោះ**វិស័យឯកជន** គឺគេត្រូវយកប្រាក់ ព្រោះគេក៏ទិញអស់ប្រាក់ដែរ ប៉ុន្តែស្នើសូមកុំឱ្យយកថ្លៃធ្វើតេស្តថ្លៃពេក។ សម្តេចតេជោបានគាំទ្រឱ្យប្រជាពលរដ្ឋតវ៉ាចំពោះក្រុមគ្រូពេទ្យរដ្ឋ ឬពេទ្យស្ម័គ្រចិត្តដែលយកឧបករណ៍រដ្ឋហើយយកប្រាក់ពីប្រជាពលរដ្ឋ ព្រោះទង្វើគឺខុសស្រឡះពីយន្តការធ្វើតេស្តរបស់រដ្ឋ។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា កម្ពុជាប្រកាន់នយោបាយ-ការបរទេសចម្រុះពណ៌ ហើយជំនួយពីប្រទេសណាក៏កម្ពុជាទទួលដែរ គ្រាន់តែយើងកំណត់នូវបង្អែកវ៉ាក់សាំងច្បាស់លាស់មួយប៉ុណ្ណោះ ។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា ប្រទេសកម្ពុជានៅតែបន្តរួមដៃជាមួយប្រទេសនានាលើពិភពលោក ជាពិសេសប្រទេសជិតខាងរួមមានប្រទេសវៀតណាម ប្រទេសថៃ ប្រទេសឡាវ ព្រមទាំងបណ្តាប្រទេសនៅក្នុងតំបន់ ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩។ កម្ពុជានៅតែមានទំនុកចិត្តនិងបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូដទៃទៀតដូចជាអង្គការសុខភាពពិភពលោក (WHO) វិទ្យាស្ថានជាតិប៉ាស្ទ័រ, CDC របស់អាមេរិក និងបណ្តាដៃគូផ្សេងទៀត អង្គការយូនីសេហ្វ (UNICEF) និងCOVAX គឺកម្ពុជាធ្វើទាំងអស់ ។ នេះហើយជានយោបាយការបរទេសចម្រុះពណ៌របស់កម្ពុជា ។ អញ្ចឹងពេលនេះលែងនិយាយអីកើតថា ហ៊ុន សែន ស្អីក៏ពឹងចិន ព្រោះជប៉ុន ឱ្យមកក៏យក អាមេរិកឱ្យមកក៏យក អង់គ្លេសឱ្យមកក៏យក អូស្ត្រាលីឱ្យមកក៏យក ។ យើងមិនដែលបដិសេធន៍ទេ គ្រាន់តែដឹងឱ្យច្បាស់ថា ប្រភពណាជាប្រភពបង្អែក ដែលផ្តត់ផ្គង់ឱ្យយើងទាំងផ្តល់ជំនួយ ផងទាំងទិញបានផង»។ **សម្តេចតេជោ ហ៊ុន សែន** គូសបញ្ជាក់ថា កម្ពុជាត្រូវការប្រភពច្បាស់លាស់ដើម្បីបញ្ចាទិញវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ យកមកចាក់ជូនប្រជាពលរដ្ឋបានទាន់ពេលវេលា ។ កម្ពុជាមិនត្រូវការប្រភពផ្តត់ផ្គង់វ៉ាក់សាំងមិនច្បាស់នោះទេ ។ វ៉ាក់សាំងជំនួយរបស់ចិនប្រភេទ Sinovac ចំនួន ១លានដូសនឹងត្រូវដឹកមកដល់ប្រទេសកម្ពុជាខណៈវ៉ាក់សាំង Johnson&Johnson ចំនួន ៩០៩.៦០០ដូសទៀតដែលជំនួយរបស់អាមេរិកតាមយន្តការ COVAX នឹងមកដល់កម្ពុជានៅថ្ងៃទី២ ខែសីហា។ ចំពោះវ៉ាក់សាំង AstraZeneca ដែលជាជំនួយរបស់រដ្ឋាភិបាលជប៉ុន ដែលនៅសល់ជិត ៦០ម៉ឺនដូស ក៏ដូចជាវ៉ាក់សាំងជំនួយរបស់រដ្ឋាភិបាលអង់គ្លេសចំនួន ៤១៥.០០០ដូសដែលជាប្រភេទAstraZeneca ដែរនោះ ក៏នឹងមកដល់ជាបន្តបន្ទាប់នៅអំឡុងខែសីហានេះដែរ។ កម្ពុជា នឹងទទួលបានវ៉ាក់សាំងប្រភេទ Sinovac ៥លានដូសបន្ថែមទៀតដែលទិញពីចិននៅក្នុងខែសីហានេះ។នៅក្នុងខែសីហានេះកម្ពុជានឹងទទួលបានវ៉ាក់ចំនួន ៧.៦៩២.៦០០ដូសទៀត ទាំងវ៉ាក់សាំងជំនួយរបស់ប្រទេសជាមិត្ត និងវ៉ាក់សាំងដែលកម្ពុជាបញ្ជាទិញពីរដ្ឋាភិបាលចិន។

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានប្រដៅដល់មេដឹកនាំសង្គមស៊ីវិលមួយចំនួន ដែលបានប្រមាថចំពោះការដឹកនាំរបស់សម្តេច ដោយលើកឡើងថា ខ្លួនបានក្លាយទៅជាមេអំបៅហើយ ប៉ុន្តែគួរកុំភ្លេចដើមកំណើតដែលកើតពីសត្វដង្កូវ។ សម្តេចតេជោបានបញ្ជាក់ថា **«អ្នកឯងកុំក្លាយទៅជាមេអំបៅ ដែលភ្លេចដើមកំណើតកើតចេញពីដង្កូវសូមចាំ»**។ សម្តេចបានចោទសួរទៅ ក្រុមមេដឹកនាំអង្គការទាំងនោះ ថាតើក្នុងចំណោមសិទ្ធិមនុស្សទាំងអស់ អ្វីជាអាទិភាពមុនគេ មុននឹងទៅដល់សិទ្ធិផ្សេងៗទៀត។ ប្រសិនបើពួកគេមិនបានដាក់សិទ្ធិរស់រានមានជីវិតមុនគេទេ គឺ «ឆ្កែសុទ្ធ» ។ ពួកអ្នកឯងនេះ គឺអ្នកឯងរៀនក្រោមដំបូលសាលារៀនដែលហ៊ុន សែន បានធ្វើឱ្យរៀនអ្នកឯងក្លាយទៅជាមេសិទ្ធិមនុស្ស បើអ្នកឯងបានរៀនក្រោមដំបូលដែល ហ៊ុន សែន គ្រប់គ្រងក្នុងរយៈពេលក្រោយឆ្នាំ១៩៧៩ អ្នកឯងមិនអាចប្រមាថមើលងាយ ហ៊ុន សែន បានទេ ព្រោះអ្នកឯងបានចេះបានដឹង ឆ្លងកាត់មហាវិទ្យាល័យ ក្រោមការដឹកនាំរបស់ ហ៊ុន សែន។ អ្នកឯងត្រូវចាំអ្នកឯងគួរខ្មាសអៀនផង។

សម្តេចតេជោ ហ៊ុន សែន បានអះអាង ការរីករាលដាលជំងឺកូវីដ១៩ អាចនឹងមិនទាន់បិទបញ្ចប់បានភ្លាមៗនោះទេ ហើយក៏មិនដឹងថាអូសបន្លាយដល់ពេលណានោះទេ។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា «សម្រាប់ខ្ញុំជឿថាមិនចប់ទេជំងឺកូវីដ១៩ អីចឹងជម្រើសដែលនៅសល់មានតែវិធីរៀនរស់ជាមួយកូវីដតាមគន្លងថ្មី ។ ជំងឺនេះអាចដូចផ្តាសាយ អេស្ប៉ាញ ដែលបច្ចុប្បន្នបន្តនៅមានជំងឺផ្តាសាយធំ ដូច្នេះត្រូវតែរៀនរស់ទៅតាមគន្លងថ្មី ដូចជារបៀបលាងដៃ របៀបពាក់ម៉ាស់ជាដើម»។

ក្នុងឱកាសនោះ **សម្តេចតេជោ ហ៊ុន សែន** បានគូសបញ្ជាក់ពីកត្តាចំនួន៥ សំខាន់ៗ ដែលនាំឱ្យ ការចាក់វ៉ាក់សាំងជូនដល់ប្រពលរដ្ឋ នឹងអាចរួចរាល់យ៉ាងយូរត្រឹមខែវិច្ឆិកា ឆ្នាំ២០២១ នេះ ស្របតាមគម្រោងរបស់រាជរដ្ឋាភិបាលចំនួន ១០លាននាក់ រួមទាំងកុមារ និងយុវជន២លាននាក់ទៀតដែលកត្តាទាំង៥នោះរួមមាន៖ **១**-កត្តាដឹកនាំមានភាពច្បាស់លាស់ ទាំងការគិត និងយន្តការអនុវត្ត **២**-កម្ពុជាមានប្រភពផ្តត់ផ្គង់ច្បាស់លាស់ដែលយកចិនជាខ្នងបង្អែកយុទ្ធសាស្ត្រឯប្រភពផ្សេងគឺជាប្រភពគាំទ្រ **៣**-កម្ពុជាមានសាច់ប្រាក់សន្សំដែលចាត់ចែងបានភ្លាមៗតែម្តង ពោលគឺបន្ទាប់ពីចុះកិច្ចសន្យាទិញលក់វ៉ាក់សាំងយើងចាប់ផ្តើមអនុវត្តតែម្តង **៤**-កម្ពុជាមានធនធានមនុស្សសម្រាប់ដំណើរការចាក់វ៉ាក់សាំងទាំងពេទ្យយោធា ពេទ្យស៊ីវិល ពេទ្យស្ម័គ្រចិត្ត បូករួមនឹងការទទួលខុសត្រូវរបស់អាជ្ញាធរ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានការទទួល ខុសត្រូវខ្ពស់ និង**៥**-មានការចូលរួមពីប្រជាជន ដែលមកទទួលវ៉ាក់សាំង និងការជួយជាថវិកាទិញវ៉ាក់សាំងដែលនេះគឺជា ចលនាជាតិក្នុងការទិញវ៉ាក់សាំង និងការទទួលយកវ៉ាក់សាំងដោយស្មគ្រ័ចិត្ត។

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ក៏បានអំពាវនាវឱ្យឪពុកម្តាយ ដែលមានកូនចៅ ដែលមានអាយុត្រូវចាក់វ៉ាក់សាំងត្រូវនាំកូនចៅមកទទួលវ៉ាក់សាំងកូវីដ-១៩ ចាប់ពីថ្ងៃនេះតទៅ និងសូមឱ្យយុទ្ធនាការនេះទទួលបាននូវភាពជោគជ័យ និងជូនពរឱ្យប្រជាពលរដ្ឋទាំងអស់បានជៀសផុតពីជំងឺក៏កាចសាហាវនេះ។

❋ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២១ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីក្នុងពិធីប្រគល់ទទួលវ៉ាក់សាំងបង្ការជំងឺកូវី-១៩ ដែលជាជំនួយរបស់ប្រជាជននិងរដ្ឋាភិបាលចក្រភពអង់គ្លេសចំនួន ៤១៥.០០០ដូស។ **សម្តេចតេជោ ហ៊ុន សែន** បានស្វាគមន៍ និងអរគុណចំពោះរដ្ឋាភិបាលនិងប្រជាជននៃចក្រភពអង់គ្លេស ដែលបានផ្តល់វ៉ាក់សាំងបង្ការជំងឺកូវី-១៩ ជូនដល់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា នាពេលនេះដែលជាជំនួយសប្បុរសធម៌ដ៏ថ្លៃថ្លា និងបង្ហាញពីសន្តានចិត្តជួយគ្នាក្នុងគ្រាលំបាកក្នុងបរិការណ៍ដែលវ៉ាក់សាំងគឺជាទំនិញយុទ្ធសាស្ត្រគន្លឹះ និងមានតម្រូវការខ្ពស់ក្នុងសមរភូមិប្រយុទ្ធ នឹងការឆ្លងរាលដាលនៃជំងឺ

សម្តេចតេជោ ហ៊ុន សែន អញ្ជើញជា អធិបតីក្នុងពិធីប្រគល់ទទួលវ៉ាក់សាំងបង្ការជំងឺកូវី-១៩ ដែលជាជំនួយ របស់ប្រជាជន និងរដ្ឋាភិបាលចក្រភពអង់គ្លេស

កូវីដ-១៩នៅគ្រប់ទិសទីនៃពិភពលោក។

សម្តេចតេជោ ហ៊ុន សែន បានគូសបញ្ជាក់ថា ដោយសារតែមេរោគ Covid-19 បានបន្តវិវត្ត និងបំប្លែងខ្លួនឥតឈប់ឈរទៅជាប្រភេទមេរោគបំប្លែងថ្មី ជាពិសេសមេរោគប្រភេទDelta ដែលបាននិងកំពុងឆ្លងរាលដាលយ៉ាងខ្លាំងនៅបណ្តាប្រទេសនានាក៏ដូចជានៅកម្ពុជាផងដែរនោះ រាជរដ្ឋាភិបាលកម្ពុជាក៏បានសម្រេចបិទខេត្តមួយចំនួន និងតំបន់ខ្លះក្នុង រាជធានីភ្នំពេញ និងដាក់ចេញនូវយុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺនេះ។ សម្តេចតេជោបានបន្តទៀតថា ដោយយល់យ៉ាងច្បាស់អំពីអត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំងរាជរដ្ឋាភិបាលបានខិតខំព្យាយាមស្វែងរកវ៉ាក់សាំង តាមយន្តការដែលមានដូចជា ទ្វេភាគីក្តី ជាពហុភាគីក្តី ដើម្បីចាក់ជូនដល់ប្រជាពលរដ្ឋ។ ចាប់តាំងពីថ្ងៃទី១០ ខែកុម្ភៈឆ្នាំ២០២១ កម្ពុជាបានចាប់ផ្តើមចាក់វ៉ាក់សាំងជូនដល់ប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ហើយចាប់ពីថ្ងៃទី១ ខែសីហា ២០២១ កម្ពុជាក៏បានសម្រេចបោះមួយជំហានទៀត គឺការចាប់ផ្តើមបើកយុទ្ធនាការចាក់វ៉ាក់សាំងដល់កុមារនិងយុវវ័យអាយុចាប់ពី១២ ដល់ក្រោម១៨ឆ្នាំ ដែលមានប្រមាណជាង២លាននាក់បន្ថែមទៀត ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងបញ្ជាក់ថា វ៉ាក់សាំងដែលជាជំនួយមនុស្សធម៌ដ៏ថ្លៃថ្លារបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាលនៃចក្រភពអង់គ្លេសនេះនឹងត្រូវប្រើប្រាស់ក្នុងយុទ្ធនាការ ចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូសនោះទី៣ ឬជូសជំរុញ ។ សម្តេចតេជោក៏ស្នើដល់ចក្រភពអង់គ្លេសផ្តល់ជំនួយមនុស្សធម៌ជាវ៉ាក់សាំងជាបន្តទៀត ក៏ដូចជាជួយសម្របសម្រួលដល់កម្ពុជាក្នុងការបញ្ជាទិញវ៉ាក់សាំង AstraZeneca បន្ថែមទៀតសម្រាប់បំពេញសេចក្តីត្រូវការចាំបាច់នាពេលខាងមុខ ។

✵ នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០២១ **សម្តេចតេជោ ហ៊ុន សែន** បានអញ្ជើញថ្លែងបើកពិធីអន្តរសាសនា ប្រឆាំងការជួញដូរមនុស្ស និងជំងឺរាតត្បាតសកលកូវីដ-១៩ ឆ្នាំ ២០២១ ។ សម្តេចមានប្រសាសន៍ថា ចាប់តាំងពីឆ្នាំ ២០១៧ ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជាតែងតែប្រារព្ធពិធីអន្តរសាសនាយ៉ាងអធិកអធមប្រឆាំងការជួញដូរមនុស្ស ។ កន្លងមកសម្តេចបានប្រគល់ភារកិច្ចនេះជូន**សម្តេចក្រឡាហោមសខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាតំណាងក្នុងនាមរាជរដ្ឋាភិបាលកម្ពុជារួមជាមួយសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ មេដឹកនាំគ្រប់និកាយសាសនា ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំមន្ត្រីរាជការពីគ្រប់ក្រសួងស្ថាប័នអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សង្គមស៊ីវិល វិស័យឯកជនរាប់ពាន់នាក់ ដើម្បីធ្វើពិធីបួងសួងតាមបែបសាសនា និងប្តេជ្ញាចិត្តរួមគ្នាលុបបំបាត់អំពើជួញដូរមនុស្សក្នុងគ្រប់រូបភាព។កម្ពុជាបានផ្អាកការជួបជុំទ្រង់ទ្រាយធំកាលពីឆ្នាំ២០២០កន្លងទៅដើម្បីអនុវត្តនូវវិធានការបង្ការទប់ស្កាត់និងដោះស្រាយបញ្ហានៃការរាតត្បាតជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ ។ នៅឆ្នាំ ២០២១ នេះ វិបត្តិកូវីដ-១៩ នៅតែបន្តឆ្លងរាតត្បាត ចំណែកការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែននានា ក៏កំពុងត្រូវបានជនឆ្លៀតឱកាសប្រើគ្រប់មធ្យោបាយទាញយកផលចំណេញពីស្ថានភាពដ៏លំបាកនេះ។ សម្តេចតេជោថ្លែងថា វេទិការអន្តរសាសនាត្រូវតែរៀបចំតាមគន្លងថ្មី ដើម្បីក្រើនរំលឹកផ្នែកស្មារតីដល់ប្រជាជនគ្រប់ជាតិសាសន៍ និងជំនឿសាសនាក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាប្រជាជននៅលើពិភពលោក ដើម្បីផ្លាស់ប្តូរ ហើយសម្របខ្លួនតាមបែបគន្លងថ្មីក្នុងសម័យកូវីដ ជាមួយនឹងការប្រកាន់ខ្ជាប់នូវស្មារតីមនុស្សធម៌ សន្តោសប្រណីយកចិត្តទុកដាក់ដល់អាយុជីវិត និងសេចក្តីថ្លៃថ្នូរនៃមនុស្សជាតិគ្រប់ជាតិសាសន៍ និងជំនឿសាសនា ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោមានមោទនភាពចំពោះការរក្សាបាននូវភាពសុខដុមរមនានៃគ្រប់ជំនឿសាសនានៅក្នុងព្រះ-រាជាណាចក្រកម្ពុជា តាមរយៈកិច្ចសហការយ៉ាងសកម្ម ជាពិសេសការអនុវត្តបានយ៉ាងខ្ជាប់ខ្ជួននូវវប្បធម៌ចែករំលែកពុំចេះរីងស្ងួតជាមួយនឹងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងគ្រាដ៏លំបាកនេះ ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តយ៉ាងសកម្មតាមរយៈដៃម្ខាងរក្សាការពារសន្តិសុខសណ្តាប់ធ្នាប់ និងស្ថិរភាពសង្គម ដើម្បីទ្រទ្រង់ជីវភាពប្រជាជន និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងដៃម្ខាងទៀតប្រយុទ្ធប្រឆាំងជំងឺរាតត្បាតសកលកូវីដ-១៩ តាមគ្រប់រូបភាព ទាំងការបង្ការទប់ស្កាត់ការព្យាបាល និងការស្តារនីតិសម្បទាជនរងគ្រោះ និងសហគមន៍ដែលទទួលរងនូវផលប៉ះពាល់ ។ ដូច្នេះការដាក់ប្រជាពលរដ្ឋ ឬអ្នកត្រឡប់មកពីតំបន់មានហានិភ័យឲ្យស្ថិតក្នុងការធ្វើចត្តាឡីស័កឬការបិទខ្ទប់តំបន់ដែលមានអត្រាឆ្លង ឬចរន្តនៃការឆ្លងខ្ពស់ ឬផ្អាកការឆ្លងដែនខុសច្បាប់នៅក្នុងដំណាក់កាលនៃការរឹតបន្តឹងវិធានការការពារសុវត្ថិភាពមិនមានន័យថា ជាការបិទសិទ្ធិសេរីភាព ឬការរើសអើង ដូចក្រុមជនអគតិបង្កបញ្ហាមួយក្រុម ដែលមាននិន្នាការប្រឆាំងផ្តាច់មុខ បាននិងកំពុងតែឃោសនាមួលបង្កាច់បំបាក់ស្មារតីប្រជាពលរដ្ឋ ប៉ុន្តែនេះគឺជាវិធានការការពារសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបាននូវកិច្ចការពារថៀសផុតពីការឆ្លងជំងឺរាតត្បាតប្រកបដោយប្រសិទ្ធភាព ។ ទន្ទឹមនេះ បន្ទាប់ពីការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋជិតសម្រេចបានតាមផែនការជាស្ថាពររាជរដ្ឋាភិបាលប្តេជ្ញាចិត្ត សម្រេចឲ្យបាននូវគោលដៅចាក់វ៉ាក់សាំងជូនកុមារ យុវវ័យ អាយុចាប់ពី ១២ និងក្រោម ១៨ឆ្នាំឲ្យបានមុនដំណាច់ឆ្នាំ ២០២១ ដើម្បីបង្កើតភាពស៊ាំ កាត់បន្ថយការចម្លងចូលក្នុងសហគមន៍ ធ្វើឲ្យប្រជាជនយើងមានជីវភាពប្រក្រតីឡើងវិញ ដើម្បីស្តារសេដ្ឋកិច្ច គ្រួសារ និងសង្គមជាតិ ៕

សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន ដឹកនាំគណៈប្រតិភូជាន់ខ្ពស់សភាកម្ពុជា ចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤២



សម្តេចចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់សភាកម្ពុជា ចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន(អាយប៉ា,AIPA)លើកទី៤២

នៅព្រឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ **សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានព្រះរាជាណាចក្រកម្ពុជាបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់សភាកម្ពុជាអញ្ជើញចូលរួមមហាសន្និបាតអន្តរ-សភាអាស៊ាន(អាយប៉ា,AIPA)លើកទី៤២ដែលប្រព្រឹត្តទៅតាមរយៈប្រព័ន្ធនិម្មិត (Virtual Meeting) ផ្សាយចេញពីរាជធានីបានដាស៊ើរីបេហ្ក៉ាន់ នៃព្រះរាជាណាចក្រព្រុយណេដារូស្សាឡាមក្រោមប្រធានបទ **«ជំរុញកិច្ចសហប្រតិបត្តិការសភាក្នុងការបញ្ចូលឌីជីថលឆ្ពោះទៅសហគមន៍អាស៊ាន២០២៥»** ។

មានប្រសាសន៍ទៅកាន់មហាសន្និបាតអន្តរសភាអាស៊ានលើកទី៤២ នេះ**សម្តេចចក្រី ហេង សំរិន** បានបញ្ជាក់ថា ស្ថិតក្នុងកាលៈទេសៈសព្វថ្ងៃនេះវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឌីជីថល ត្រូវបានគេមើលឃើញថា កំពុងដើរតួនាទីកាន់តែសំខាន់ក្នុងការជំរុញសន្ទុះនៃកំណើនសេដ្ឋកិច្ចឡើងវិញនៅក្រោយវិបត្តិជំងឺកូវីដ-១៩ ក៏ដូចជាជំរុញកំណើនសេដ្ឋកិច្ចថ្មីប្រកបដោយចីរភាព និងភាពធន់ជាងមុន ទៅនឹងវិបត្តិផ្សេងៗ។ ពិភព-លោកក្នុងបរិការណ៍នៃបដិវត្តឧស្សាហកម្មជំនាន់ទី៤ កំពុងមានការរីកចម្រើន និងវិវឌ្ឍយ៉ាងឆាប់រហ័ស លើផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឌីជីថល។

សម្តេចចក្រីប្រធានរដ្ឋសភាក៏បានកោតសរសើរចំពោះក្រុមប្រឹក្សានីតិប្បញ្ញត្តិនៃប្រទេសព្រុយណេដារូស្សាឡាម ជាពិសេស ឯកឧត្តម **ប៉េហ៊ីន ជាតូ អាប់ឌុល ៉ាម៉ានធីប** ប្រធានមហាសន្និបាតអាយប៉ា លើកទី៤២ ដែលបានខិតខំប្រឹងប្រែងនិងយកចិត្តទុកដាក់ខ្ពស់ក្នុងការជំរុញកិច្ចសហប្រតិបត្តិការសភាលើបរិយាប័ន្នឌីជីថល ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥។សម្តេចចក្រី**ហេង សំរិន** បានថ្លែងទៀតថា សម្រាប់កម្ពុជាវិញកាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលឆ្នាំ២០២១-២០៣៥"** ក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើកសំដៅជំរុញការទទួលយក និងការធ្វើបរិវត្តកម្មឌីជីថល។គោលនយោបាយនេះ នឹងជួយជំរុញការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩។ **សម្តេចចក្រី ហេង សំរិន** ក៏បានអំពាវនាវដល់អាស៊ាន និងអាយប៉ាជំរុញនិងលើកកម្ពស់ឌីជីថលរូបនីយកម្ម ដែលជាកាលានុវត្តភាពដ៏សំខាន់និងចាំបាច់ក្នុងការជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ចថ្មី និងការលើកកម្ពស់សុខុមាលភាពសង្គម ផ្អែកលើប្រក្រតីភាពតាម គន្លងថ្មី។ សម្តេចចក្រីបានស្នើដល់អ្នកពាក់ព័ន្ធ ត្រូវបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការតំបន់លើការតភ្ជាប់ឌីជីថល ការធ្វើពាណិជ្ជកម្មឌីជីថលឆ្លងកាត់ព្រំដែន សន្តិសុខ និងសុវត្ថិភាពនៃលំហូរទិន្នន័យ សន្តិសុខប្រព័ន្ធអ៊ីនធឺណិត និងការធ្វើឌីជីថលូបនីយកម្មប្រកបដោយបរិយាប័ន្ន។ឆ្លៀតនៅក្នុងឱកាសនេះ**សម្តេចចក្រីហេង សំរិន**ក៏បានអញ្ជើញសមាជិកអន្តរ-សភាអាស៊ានទាំងអស់ ចូលរួមកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ និងកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី១១នៅប្រទេសកម្ពុជានាចុងឆ្នាំនេះផងដែរ។

គួរំលឹកថា អន្តរសភាអាស៊ាន ដែលហៅកាត់ថា អាយប៉ា(AIPA) ជាអង្គការអន្តរសភា តំណាងស្ថាប័ននីតិប្បញ្ញត្តិ នៃបណ្តាប្រទេសជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(ASEAN)ដែលមានប្រទេសព្រុយណេដារូស្សាឡាម កម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។ អន្តរសភាអាស៊ាន ជាការប្រមូលផ្តុំសម្លេងប្រជាពលរដ្ឋក្នុងសហគមន៍អាស៊ាន ជាដៃគូរបស់អាស៊ាន ក្នុងការជំរុញឱ្យសម្រេចបាននូវគោលដៅសហគមន៍អាស៊ានតែមួយ ។ មហាសន្និបាតអន្តរសភាអាស៊ាន បានប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ដោយប្រទេសជាសមាជិកតាមវេនលំដាប់អក្ខរក្រម នៃឈ្មោះប្រទេសតាមអក្សរឡាតាំង។

នៅឆ្នាំ២០២២ខាងមុខនេះ សភានៃព្រះរាជាណាចក្រកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះមហាសន្និបាតលើកទី៤៣។ ពិធីប្រគល់តួនាទីជាប្រធានប្តូរវេនអាយប៉ាដល់សភាកម្ពុជា ប្រារព្ធធ្វើនៅចុងបញ្ចប់នៃពិធីបិទមហាសន្និបាតអាយប៉ា លើកទី៤២ នេះ។

សម្តេចក្រឡាហោម ស ខេង ផ្តល់អនុសាសន៍សំខាន់ៗមួយចំនួន សម្រាប់ការងាររដ្ឋបាលថ្នាក់ក្រោមជាតិ

សម្តេចក្រឡាហោម ស ខេង អញ្ជើញជាអធិបតីក្នុងពិធីប្រគល់រថយន្ត Ford Ranger Pick-up ចំនួន៨៧គ្រឿង ដល់ស្នងការដ្ឋាននគរបាលខេត្ត

កាលពីថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១ ក្នុងពេលអញ្ជើញជាអធិបតីក្នុងពិធីប្រគល់រថយន្ត Ford Ranger Pick-up ចំនួន៨៧គ្រឿង ដល់ស្នងការដ្ឋាននគរបាលខេត្ត ដើម្បីបែងចែកជូនអធិការដ្ឋាននគរបាលក្រុង ស្រុក **សម្តេចក្រឡាហោម ស ខេង** បានថ្លែងអំពីយុទ្ធនាការបង្ក្រាបបទល្មើសគ្រឿងញៀនដែលក្នុងមួយរយៈកន្លងនេះទទួលបានជោគជ័យគួរឲ្យកត់សម្គាល់។

សម្តេចក្រឡាហោម ស ខេង បានថ្លែងបញ្ជាក់ថា បទល្មើសគ្រឿងញៀននេះបានថយចុះបន្តិច ប៉ុន្តែក្រុមឧក្រិដ្ឋជននៅតែឆ្លៀតឱកាសលួចកែច្នៃ ផលិត និងនាំចូលសារធាតុញៀន អាភៀន ពីបណ្តាប្រទេសជុំវិញ ពិសេសពីតំបន់ត្រីកោណមាសមកកម្ពុជា ធ្វើការកែច្នៃ និងផលិតគ្រឿងញៀន កើនឡើងជាងពេលមុន ។ សម្តេចក្រឡាហោមថ្លែងបន្តថា៖ «ចាប់តាំងពីយុទ្ធនាការបង្ក្រាបគ្រឿងញៀនដំបូងឆ្នាំ២០១៧ មកដល់ពេលនេះ គិតទាំងអាភៀន និងសារធាតុគីមីផ្សំ មានជាង ១១តោន ហើយក៏មិនដឹងថា រួចផុតចេញពីយើងទៅប៉ុន្មានទៀតដែរ។ប៉ុន្តែទោះជាយ៉ាងណានេះគឺជាលទ្ធផលដែលកើតចេញពី ឆន្ទៈមោះមុតនៃការបំពេញភារកិច្ចជារួមរបស់កងកម្លាំងនគរបាលជាតិ និងមន្ត្រីរាជការពាក់ព័ន្ធទាំងអស់» ។

ទាក់ទងនឹងបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ **សម្តេចក្រឡាហោមសខេង** បានគូសបញ្ជាក់ថា រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំសង្កាត់ ត្រូវបានចាត់ទុកថាជារដ្ឋបាលដែលនៅជិតប្រជាពលរដ្ឋបំផុត ពោលគឺបេសកកម្មរបស់ថ្នាក់ក្រោមជាតិនេះក៏មិនខុសពីថ្នាក់ជាតិដែរ ហើយរឹតតែសំខាន់ជាងថ្នាក់ជាតិទៅទៀត នៅត្រង់ថាពួកគាត់នៅជាមួយនឹងប្រជាពលរដ្ឋ ប្រជាពលរដ្ឋអាចដឹងថាពួកគាត់ធ្វើល្អ និងមិនធ្វើល្អដោយងាយ ។ សម្តេចក្រឡាហោម បានថ្លែងថា៖ «ខ្ញុំលើកយោបល់ថា នៅថ្នាក់ឃុំ យើងត្រូវផ្តោតលើមុខសញ្ញា៨ គឺមេឃុំ ចៅសង្កាត់, ស្មៀនឃុំ ស្មៀនសង្កាត់, ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាល និងមេភូម។ យើងត្រូវតែយកចិត្តទុកដាក់ឱ្យពួកគាត់ធ្វើការងារបម្រើប្រជាពលរដ្ឋឱ្យបានល្អ ដែលទាមទារការផ្តល់នូវការណែនាំ ទិសដៅគោលការណ៍ វិធានការនានា និងមធ្យោបាយធ្វើការ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញការងារ ។ បើមិនទាន់មានអគារប៉ុស្តិ៍រដ្ឋបាលទេ យើងត្រូវធ្វើអគារជូនគាត់ ។ សម័យនេះយើងមិនអាចធ្វើការក្រោមដើមឈើទៀតបានទេ។ មកដល់ពេលនេះ យើងសាងសង់អគាររដ្ឋបាលប៉ុស្តិ៍រដ្ឋបាលឃុំសង្កាត់បានច្រើនហើយ គឺនៅសល់តែប្រមាណ៨០កន្លែងទៀតទេ ក្នុងចំណោម ១.៦៦៤ឃុំ សង្កាត់ ។

សម្តេចក្រឡាហោម ក៏បានលើកឡើងផងដែរពាក់ព័ន្ធការបណ្តុះ-បណ្តាលធនធានមនុស្សជាមន្ត្រីស្មៀនឃុំសង្កាត់ និងមន្ត្រីកងកម្លាំងនគរបាលនៅមូលដ្ឋាន ព្រមទាំងបានបន្ថែមថា អធិការដ្ឋាននគរបាល និងប៉ុស្តិ៍នគរបាលរដ្ឋបាល ក្រសួងក៏នឹងមានការគិតគូរបន្ថែមទៀត ដូចជា ការវិភាជន៍ក្របខណ្ឌ និងមុខងារឱ្យបានសមស្រប ដោយផ្អែកលើកត្តា ភូមិសាស្ត្រ និងប្រជាសាស្ត្រ ពោលគឺផ្អែកលើចំនួនប្រជា-ពលរដ្ឋតិច ឬច្រើន និងវិសាលភាពទឹកដីរដ្ឋបាលនោះធំឬតូច ឬមានភាពស្មុគស្មាញ ជាដើម ដើម្បីដាក់ពង្រាយបរិមាណកងកម្លាំងឱ្យត្រូវនឹងស្ថានភាពជាក់ស្តែង។ **សម្តេចក្រឡាហោម ស ខេង** បានទទួលស្គាល់ថា នៅភ្នំពេញ នគរបាលប៉ុស្តិ៍មានការខ្វះខាត ប៉ុន្តែត្រូវទទួលខុសត្រូវបំពេញការងារច្រើន ដែលទាមទារឱ្យមានការគិតគូឡើងវិញ ។

សម្តេចក្រឡាហោមថ្លែងថា កន្លងមក សម្តេចក៏បានណែនាំឱ្យមានការគិតគូរអំពីអង្គភាពនីមួយៗនៅថ្នាក់ក្រសួង តើមានតម្រូវការមន្ត្រីនគរបាលប៉ុន្មាននាក់ឱ្យពិតប្រាកដ ដើម្បីដាក់មន្ត្រីឱ្យសមល្មម ហើយរំលែកក្របខណ្ឌនេះទៅឱ្យប៉ុស្តិ៍រដ្ឋបាលឃុំសង្កាត់ និងអធិការដ្ឋាននគរ-បាលវិញ ដែលនេះជាវិធានការកាត់បន្ថយការស្នើសុំក្របខណ្ឌបន្ថែមសម្រាប់កងកម្លាំងនគរបាលជាតិពីរាជរដ្ឋាភិបាល ។ បញ្ហាដែលកំពុងដោះស្រាយនេះ មិនមែនកើតឡើងដោយសារកំហុសនរណាម្នាក់នោះទេ ពីព្រោះកម្ពុជាបានឆ្លងកាត់ប្រវត្តិសាស្ត្រដែលរដ្ឋចាប់ផ្តើមបំពេញ ការងារជាមួយនឹងភាពខ្វះខាតធនធានមនុស្ស ទើបបណ្តាលឱ្យជួបស្ថានភាពខ្វះតែសល់ ពោលគឺខ្វះអ្នកមានសមត្ថភាពធ្វើការ តែសល់អ្នកមិនមានសមត្ថភាពធ្វើការ ។

សម្តេចក្រឡាហោមបានគូសបញ្ជាក់ថា មកដល់ពេលនេះអត្រាឆ្លងជំងឺកូវីដ-១៩ លើពិភពលោកនៅតែស្ថិតក្នុងកម្រិតខ្ពស់នៅឡើយ ខណៈប្រទេសកម្ពុជា និងបណ្តាប្រទេសជាច្រើនបានរកឃើញវត្តមានមេរោគបំប្លែងខ្លួនថ្មី ដែលតា ។ សម្តេចក្រឡាហោមថ្លែងថា ជាការពិតហើយយើងត្រូវគោរពតាមវិធានការសុខាភិបាល ប៉ុន្តែទន្ទឹមគ្នានេះ យើងក៏ត្រូវយកចិត្តទុកដាក់បំពេញភារកិច្ចជាចាំបាច់ ដើម្បីថែរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋ ។ **សម្តេច-ក្រឡាហោម ស ខេង** បានសម្តែងក្តីសង្ឃឹមជឿជាក់ថាទោះបីជាត្រូវបន្តប្រឈមមុខនឹងការរីករាលដាលជំងឺកូវីដ-១៩ ដែលមិនមានភាពប្រាកដប្រជាយ៉ាងណាក្តីថ្នាក់ដឹកនាំ មន្ត្រីរាជការស៊ីវិល និងកងកម្លាំងទាំងអស់ នឹងរួមគ្នាបន្តខិតខំបំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវ ដើម្បីបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរថែមទៀត ៕

សម្តេចពិជ័យសេនា ទៀ បាញ់ ៖ ជំនួយវ៉ាក់សាំងរបស់ចិន រួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងកាត់ផ្តាច់ការឆ្លងជំងឺកូវីដ-១៩

__សម្តេចពិជ័យសេនា ទៀ បាញ់__ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អញ្ជើញជាអធិបតីនៅក្នុងពិធីប្រគល់និងទទួលវ៉ាក់សាំងកូវីដ១៩ ប្រភេទ ស៊ីណូហ្វាម ចំនួន ៥០ម៉ឺនដូស

នារសៀលថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១នេះ**សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានអញ្ជើញជាអធិបតីនៅក្នុងពិធីប្រគល់ និងទទួលវ៉ាក់សាំងកូវីដ១៩ ប្រភេទ ស៊ីណូហ្វាម ចំនួន ៥០ម៉ឺនដូស ដែលជាជំនួយរបស់កងទ័ពរំដោះប្រជាជនចិន ជំហានទី៣ ជូនដល់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដោយមានការចូលរួមជាតំណាងរដ្ឋាភិបាលចិន ឯកឧត្តម Wang Wentian ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជាផងដែរ ។ **សម្តេចពិជ័យសេនា ទៀ បាញ់** បានលើកឡើងថាការទទួលវ៉ាក់សាំងដំណាក់កាលទី៣ចំនួន៥០ម៉ឺនដូស ដែលជាអំណោយរបស់រដ្ឋាភិបាលចិនតាមរយៈក្រសួងការពារប្រទេសចិន ជូនរដ្ឋាភិបាលកម្ពុជាពិតជាបានចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងកាត់ផ្តាច់នៃការចម្លងជំងឺកូវីដ១៩ ប្រភេទថ្មី Delta នៅក្នុងសហគមន៍កម្ពុជាយ៉ាងសក្តិសិទ្ធ ។ **សម្តេចពិជ័យសេនា ទៀ បាញ់** បានថ្លែងថា ៖ «ការទទួលវ៉ាក់សាំងដំណាក់កាលទី៣ ចំនួន ៥០ម៉ឺនដូស ដែលជាអំណោយរបស់រដ្ឋាភិបាលចិនតាមរយៈក្រសួងការពារប្រទេសចិន ផ្តល់ជូនក្រសួងការពារជាតិកម្ពុជានាថ្ងៃនេះពិតជារួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការទប់ស្កាត់និងកាត់ផ្តាច់នៃការឆ្លងជំងឺកូវីដ១៩ ប្រភេទថ្មី Delta នៅក្នុងសហគមន៍នៅកម្ពុជាយ៉ាងសក្តិសិទ្ធ។ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងការពារជាតិ កងទ័ពនិងប្រជាជនកម្ពុជាពិតជាដឹងគុណដ៏ជ្រាលជ្រៅចំពោះរដ្ឋាភិបាល កងទ័ព និងប្រជាជនចិន ដែលបានផ្តល់អំណោយ និងជំនួយសប្បុរសជាច្រើន ជាពិសេសការផ្តល់វ៉ាក់សាំងការពារជំងឺ កូវីដ១៩ ចំនួន៥០ម៉ឺនដូស សម្រាប់ក្រសួងការពារជាតិប្រើប្រាស់តាមបទបញ្ជារបស់រាជរដ្ឋាភិបាល ក្នុងកាលៈទេសៈដ៏លំបាកនេះ» ។ សម្តេចពិជ័យសេនាបានថ្លែងបន្តថា ស្ថានភាពបច្ចុប្បន្ននេះ គឺពោរពេញទៅ ដោយភាពមិនប្រាកដប្រជា ដោយសារមេរោគកូវីដ១៩ បានបន្តវិវត្ត និងបំប្លែងខ្លួនឥតឈប់ឈរទៅជាប្រភេទមេរោគបំប្លែងថ្មី ជាពិសេសមេរោគ ប្រភេទ Delta ដែលបាននិងកំពុងឆ្លងរាលដាលយ៉ាងខ្លាំងនៅតាមបណ្តាប្រទេសនានាក៏ដូចជានៅកម្ពុជា។ បច្ចុប្បន្ននេះ កម្ពុជាក៏ដូចជាបណ្តាប្រទេសជាច្រើនបាននឹងកំពុងផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើយុទ្ធនាការចាក់វ៉ាក់សាំងដែលជាដំណោះស្រាយដ៏សមស្របបំផុតក្នុងការប្រយុទ្ធនិងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ១៩រួមទាំងមេរោគបំប្លែងថ្មីប្រភេទ Delta ផងដែរ ។ **សម្តេចពិជ័យសេនា ទៀ បាញ់** បានគូសបញ្ជាក់ថា «ដោយយល់យ៉ាងច្បាស់លាស់អំពីអត្ថប្រយោជន៍ដ៏សំខាន់នេះ រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃរបស់ **សម្តេចតេជោ ហ៊ុន សែន** បានខិតខំព្យាយាមស្វែងរកវ៉ាក់សាំងតាមរយៈយន្តការដែលមានជាទ្វេភាគីក្តី ជាពហុភាគីក្តី ក្នុងរូបភាពជាជំនួយមនុស្សធម៌ក្តី និងជាការបញ្ជាទិញដោយផ្ទាល់ក្តី ដើម្បីធានាបានចំនួនវ៉ាក់សាំងគ្រប់គ្រាន់ ទាន់ពេលវេលាតាមផែនការដែលបានកំណត់» ។

ក្នុងពិធីប្រគល់ និងទទួលវ៉ាក់សាំងនេះ ឯកឧត្តម Wang Wentian បានបញ្ជាក់ថា៖ «ក្នុងនាមជាមិត្ត **"ជែកថែប"** និងសហគមន៍វាសនារួមភាគីចិនបានចាត់ទុកបញ្ហាប្រឈមក៏ដូចជា ការលំបាកដែលមាននៅកម្ពុជា ជាបញ្ហាប្រឈមក៏ដូចជាការលំបាករបស់ខ្លួន។ ភាគីចិននឹងបន្តផ្តល់ជំនួយជាវ៉ាក់សាំង បរិក្ខារវេជ្ជសាស្ត្រ និងការគាំទ្រជាសម្ភារៈជូនដល់កម្ពុជាតាមលទ្ធភាពដែលអាចធ្វើបាន បន្តធ្វើជាបង្អែកយុទ្ធសាស្ត្រក្នុងការផ្គត់ផ្គង់វ៉ាក់សាំងជូនដល់កម្ពុជា» ។

គិតត្រឹមថ្ងៃទី២៣ ខែសីហា ចិនបានផ្តល់វ៉ាក់សាំងកូវីដ-១៩ដល់កម្ពុជាសរុបចំនួន ២២,២លានដូស ដែលមានទាំងជំនួយ និងការផ្គត់ផ្គង់តាមការបញ្ជាទិញ ដែលលើកនេះគឺជាជំហានទី៦ ដែលចិនបានផ្តល់ជំនួយជាវ៉ាក់សាំងដល់កម្ពុជា។ រហូតមកដល់បច្ចុប្បន្ននេះ ចំនួនវ៉ាក់សាំងដែលជាជំនួយរបស់ចិនមានចំនួនរហូតដល់ ៣,៧លានដូស ។ ចិនបានគោរពតាមពាក្យសន្យា ដោយជួយផ្តល់ការគាំទ្រដ៏សំខាន់សម្រាប់ការបង្កើតប្រព័ន្ធភាពស៊ាំជូនដល់កម្ពុជា និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារអាយុជីវិតរបស់ប្រជាជនកម្ពុជា ៕

ឯកឧត្តម គន់ គីម ៖ សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត តែងផ្សារភ្ជាប់សុខទុក្ខជាមួយប្រជាជនជានិច្ច

*ឯកឧត្តម នាយឧត្តមសេនីយ៍ **គន់ គីម** អញ្ជើញផ្តល់ជំនួយជាថវិកា អង្ករ និងសម្ភារៈប្រើប្រាស់មួយចំនួនទៀត ដែលជាអំណោយរបស់ **សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនដល់អតីតយុទ្ធជនកម្ពុជា ១៤១គ្រួសារ នៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ*

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា បានផ្តល់ជំនួយជាថវិកា អង្ករ និងសម្ភារៈប្រើប្រាស់មួយចំនួនទៀត ជូនដល់អតីតយុទ្ធជនកម្ពុជា ១៤១គ្រួសារ ដែលកំពុងរស់នៅលើដីសម្បទានសង្គមកិច្ចស្ថិតនៅក្នុងឃុំក្រយាស្រុកសន្ទុកខេត្តកំពង់ធំ។ជំនួយនេះត្រូវបានឯកឧត្តម នាយឧត្តមសេនីយ៍ **គន់ គីម** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រីអនុប្រធាន និងជាអគ្គលេខាធិការសមាគមអតីតយុទ្ធជន យកទៅប្រគល់ជូនដល់ដៃអតីតយុទ្ធជននៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ នេះ ដោយក្នុងមួយគ្រួសារទទួលបានថវិកាចំនួន ៤០ម៉ឺនរៀល, អង្ករ ៣០គីឡូក្រាម និងសម្ភារៈប្រើប្រាស់មួយចំនួនទៀត ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **គន់ គីម** បានពាំនាំនូវក្តីនឹករលឹក និងក្តីបារម្ភរបស់**សម្តេចតេជោ ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ចំពោះអតីតយុទ្ធជនទាំងអស់ដោយសម្តេចតែងដាស់តឿនរូបលោកជាសេនាធិការ ឱ្យពិនិត្យជាប់ប្រចាំលើជីវភាព និងការរស់នៅរបស់អតីតយុទ្ធជន ជាពិសេសអំឡុងពេលនៃការរីករាតត្បាតជំងឺកូវីដ១៩នេះ។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានគូសបញ្ជាក់ថា«សម្តេចទាំងទ្វេលោកនឹករលឹក និងគិតគូរចំពោះសុខទុក្ខបងប្អូនអតីតយុទ្ធជនរបស់យើងជាប់ជានិច្ច។ លោកតែងក្រើនរំលឹកខ្ញុំជាប់ជាប្រចាំឱ្យពិនិត្យតាមដានការរស់នៅ និងជីវភាពរបស់បងប្អូន មិនអាចឱ្យបងប្អូនអតីតយុទ្ធជនយើងខ្វះខាត អត់ឃ្លាននោះទេ ទោះលំបាកយ៉ាងណាក៏ត្រូវតែជួយបងប្អូនអតីតយុទ្ធជនយើង ។ សម្តេចទាំងទ្វេលោកគិតគូរនិងយកចិត្តទុកដាក់លើបងប្អូនអតីតយុទ្ធជនយើងខ្លាំងណាស់» ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **គន់ គីម** ក៏បានលើកបង្ហាញពីកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដែលមាន**សម្តេចតេជោ ហ៊ុន សែន** ជាប្រមុខលើការងារប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ក៏ដូចជាការប្រឹងប្រែងរកវ៉ាក់សាំងបង្ការជំងឺកូវីដ១៩ចាក់ជូនប្រជាពលរដ្ឋទូទៅកងកម្លាំងប្រដាប់អាវុធមន្ត្រីរាជការក៏ដូចជាអតីតយុទ្ធជន។ក្រោមកិច្ចប្រឹងប្រែងក្រោមការគិតគូរដ៏ច្បាស់លាស់ និងប្រាកដនិយមរបស់ សម្តេចតេជោបានធ្វើឱ្យកម្ពុជាទទួលបាន លទ្ធផលល្អលើការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩នេះ។ ឯកឧត្តមទេសរដ្ឋមន្ត្រី **គន់ គីម** បានបន្តក្រើនរំលឹកក្រុមគ្រួសារអតីតយុទ្ធជន ឱ្យយកចិត្តទុកដាក់បង្ការជំងឺកូវីដ១៩ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានសុខាភិបាល ជាពិសេសអនុវត្តន៍តាមអនុសាសន៍ណែនាំរបស់**សម្តេចតេជោ ហ៊ុន សែន «៣កុំ ៣ការពារ»** ៕

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ឃួន ញ៉ិល** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី១ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមការងារគណបក្សថ្នាក់កណ្តាលចុះមូលដ្ឋានខេត្តកំពង់ធំ បានអញ្ជើញជាអធិបតីភាព ដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំជាមួយគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តកំពង់ធំ និងប្រធានគណបក្សស្រុក ក្រុងទាំងអស់ ភូមិត្រពាំងស្វាយ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ថ្លែងថា ការងារថ្មីចំពោះមុខ គណបក្សខេត្តត្រូវអនុវត្តតាមសេចក្តីណែនាំ ស្តីពីការងារឃោសនាឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ របស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រកបដោយលទ្ធផលល្អ និងធានាទទួលបានជ័យជំនះតាមការប្តេជ្ញាចិត្តរបស់គណបក្ស ។

ថ្ងៃទី០៧ខែសីហា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង អមដំណើរដោយឯកឧត្តម **ស៊ុន សុវណ្ណារិទ្ធិ** អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងក្រុមការងារបានអញ្ជើញជួបពិភាក្សាការងារពីសភាពកាណ៍ផ្សេងៗទូទៅក្នុងខេត្ត ពិសេសការងាររៀបចំមជ្ឈមណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាលពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃវិញតាមព្រំដែនគោក តាមសារាចរណែនាំរបស់រាជរដ្ឋាភិបាល នៅស្រុករលាប្អៀរខេត្តកំពង់ឆ្នាំង ។

ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២១ លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តស្វាយរៀង បានអញ្ជើញនាំយកផ្លែមៀន (តាង៉ែន) ចំនួន១០តោន ប្រគល់ជូនដល់រដ្ឋបាលក្រុង-ស្រុកទាំង៨ មន្ទីរពេទ្យបង្អែកខេត្តស្វាយរៀង មន្ត្រីសុខាភិបាល និង កងម្លាំងទាំងបី។ លោកជំទាវបាននាំមកនូវការសាកសួរសុខទុក្ខពីសំណាក់ **សម្តេចតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** នូវក្តីនឹករលឹកនិងការគិតគូរអំពីសុខទុក្ខ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង។

ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាអគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក និងឯកឧត្តម **ម៉ែន កុសល្យ** អភិបាលខេត្តឧត្តរមានជ័យ បានដឹកនាំក្រុមការងារចុះពិនិត្យមើលវឌ្ឍនភាព នៃការរៀបចំមណ្ឌលព្យាបាលជំងឺកូវីដ១៩ កម្រិតស្រាលក្នុងក្រុងសំរោង និងបន្តចុះពិនិត្យមើលការរៀបចំមណ្ឌលធ្វើចត្តាឡីស័ក នៅស្រុកអន្លង់វែង សម្រាប់ទទួលពលករមកពីប្រទេសថៃ។

សកម្មភាពសមាជិកវរជួសតា-ព្រឹទ្ធសតា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី២ ខែសីហា ឆ្នាំ២០២១ តបតាមការអញ្ជើញរបស់ ឯកឧត្តម **ជាតូ អ៊ីវ៉ាន់ ពើហ៊ីន យូស៊ូហ៍** រដ្ឋមន្ត្រីការបរទេសទី២ របស់ព្រុយណេដារ៉ូស្សាឡាម ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៤ (54th AMM) តាមប្រព័ន្ធវីដេអូ។ កិច្ចប្រជុំបានពិភាក្សាលើបញ្ហានានាពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ាន ការលើកកម្ពស់សមាហរណកម្មតំបន់ ទិដ្ឋភាព ភាពនយោបាយនិងសន្តិសុខ និងបញ្ហាចាំបាច់បន្ទាន់ដទៃទៀតដែលជាការយកចិត្តទុកដាក់និងការបារម្ភរួមសម្រាប់តំបន់អាស៊ានរួមទាំងបញ្ហាទំនាក់ទំនងខាងក្រៅផងដែរ។ក្នុងឱកាសនោះឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានសង្កត់ធ្ងន់លើសារៈ សំខាន់នៃការធានាថា ការចូលរួមរបស់អាស៊ានជាមួយដៃគូខាងក្រៅ គឺគាំទ្រដល់មជ្ឈភាពអាស៊ាន ដែលស្របនឹងគោលការណ៍អាស៊ាន រួមមានទស្សនៈវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP)។

ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១ ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហោ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានដឹកនាំក្រុមការងារបច្ចេកទេសក្រសួងសុខាភិបាល ដែលមានការអញ្ជើញចូលរួមពីអាជ្ញាធរមូលដ្ឋានខេត្ត ចុះពិនិត្យមន្ទីរពិសោធន៍ថ្នាក់តំបន់ ដែលទើបសាងសង់រួច ដែលស្ថិតនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប និងមន្ទីរពេទ្យខេត្តបាត់ដំបង។ ឯកឧត្តមរដ្ឋមន្ត្រីបានផ្តល់ការណែនាំអំពីការពង្រឹងបន្ថែមទៀតចំពោះការធ្វើតេស្ត និងកាត់បន្ថយការបញ្ជូនសំណាកទៅភ្នំពេញ និងត្រូវប្រើប្រាស់ថែទាំម៉ាស៊ីន វិភាគរកវីរុសកូវីដ-១៩ (PCR Machine) ឱ្យបានយូរអង្វែង។

ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **ខៀវ កាញារីទ្ធ** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានស្រុកកោះសូទិន ខេត្តកំពង់ចាម រួមជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង អញ្ជើញនាំ យកអំណោយជាថវិកា និងគ្រឿងឧបភោគបរិភោគ ជូនដល់ប្រជាពលរដ្ឋដែលកំពុងជាប់ចត្តាឡីស័កនៅតាមខ្នងផ្ទះ នៅឃុំព្រៃកតានង់ ស្រុក កោះសូទិន ខេត្តកំពង់ចាម ។

ឯកឧត្តម **ង្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានថ្លែងក្នុងសិក្ខាសាលាអនឡាញស្តីពី **«ការរៀបចំផែនការសម្រាប់ទីក្រុងឆ្លាត (Virtual Conference on Smart City Planning)»** កាលពីថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០២១ ថា ទីក្រុងឆ្លាតមិនត្រឹមតែជាទីក្រុងដែលមានការជឿនលឿនផ្នែកបច្ចេកវិទ្យា (Advanced Technology) ប៉ុណ្ណោះទេ តែគឺជាទីក្រុងដែលមនុស្សអាចរស់នៅបាន (Liveable City)។ ឯកឧត្តមបានសម្តែងនូវការគាំទ្រចំពោះគំរោងរបស់ប្រទេសជាសមាជិកអាស៊ាន សម្រាប់ការបង្កើតបណ្តាញទីក្រុងឆ្លាត (ASEAN Smart City Network) ដែលមានការគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ និងនវានុវត្តន៍ក្នុងការផ្តល់សេវាសាធារណៈ រួមមានៈ ការងារស្បៀង ជម្រកហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវអគ្គីសនី ទឹកស្អាត) អប់រំ សុខាភិបាល ការធ្វើដំណើរ ទំនាក់ទំនង សន្តិសុខ សុវត្ថិភាព សុខុមាលភាព បរិស្ថាន ។ល។ ដែលអាចឆ្លើយតបបានតាមសំណូមពរ និងតម្រូវការចាំបាច់របស់ប្រជាជនរស់នៅក្នុងទីក្រុង ដែលចេះតែកើនឡើងជាលំដាប់នៅពេលអនាគត។

ថ្ងៃទី៤ ខែសីហា ឆ្នាំ ២០២១ ឯកឧត្តម **ស្សោច សាវ៉ាត** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មាធិការគណបក្សខេត្តព្រៃវែង អមដំណើរដោយឯកឧត្តមលោកជំទាវ សមាជិកគណៈអចិន្ត្រៃយ៍គណបក្សខេត្ត បានអញ្ជើញចុះជួបសំណេះសំណាល និងជូនថវិកាដល់គណបក្សស្រុកកំចាយមារ ដើម្បីសម្រួលដល់ការរៀបចំចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ ចំនួន ២ លានរៀល ជូនមន្ទីរពេទ្យបង្អែកស្រុកចំនួន ៣ លានរៀល អាល់កុល ២ កាន ម៉ាស់ ២ កេសធំ និងឱសថបុរាណចិនចំនួន៥០០ ប្រអប់ សម្រាប់ការពារ ទប់ស្កាត់ការរីករាលដាល និងព្យាបាលជម្ងឺកូវីដ-19 ។ ឯកឧត្តមបានថ្លែងកោតសរសើរដល់គណបក្សស្រុក រដ្ឋបាលស្រុក និងមន្ត្រី/ បុគ្គលិកពេទ្យដែលបានខិតខំប្រឹងប្រែង យកចិត្តទុកដាក់អប់រំ ណែនាំដល់ប្រជាពលរដ្ឋឲ្យ អនុវត្តនូវវិធានការ៣ការពារ ៣កុំ និងបានថែទាំ ព្យាបាលអ្នកជម្ងឺឲ្យបានជាសះស្បើយជាបន្តបន្ទាប់។

សកម្មភាពសមាជិកព្រឹទ្ធសភា-រដ្ឋសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ម៉ា ឈឿន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា តំណាងរាស្ត្រមណ្ឌលកំពង់ចាម អនុប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកំពង់ចាម និងជាប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយ ស្រុកជើងព្រៃ និងលោកជំទាវកិត្តិបណ្ឌិត **អ៊ុក ម៉ាលី** ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បាននាំយកនូវគ្រឿង ឧបភោគ បរិភោគ និងសម្ភារៈមួយចំនួនមានដូចជា៖ អង្ករ១២០បាវ, ត្រីខកំប៉ុង១០០យួរ ទឹកត្រី១០០យួរ ទឹកស៊ីអ៊ីវ១០០យួរ ទឹកបរិសុទ្ធ១០០យួរ ម៉ាស២៥០ប្រអប់ អាកុល៣០០លីត និងថវិកា២លានរៀល ដើម្បីចូលរួមក្នុងការទប់ស្កាត់ការីករាលដាល នៃជំងឺកូវីដ-១៩ ក្នុងស្រុកជើងព្រៃ។

ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **ម៉ម ប៊ុនឆាង** សមាជិកគណៈកម្មាធិការកណ្តាលអនុប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តនិងទទួលជួយស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រធានគណៈកម្មការទី១០ នៃព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយសម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ទៅផ្តល់ជូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតកំពុងសម្រាកព្យាបាលជំងឺកូវីដ-១៩ និងកំពុងធ្វើចត្តាឡីស័កនៅតាមផ្ទះចំនួន ៦៣គ្រួសារ ស្ថិតនៅឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលរួមមាន៖ អង្ករ២០គីឡូ មី០១កេសតូច ទឹកត្រី ០១យួរ ទឹកស៊ីអ៊ីវ ០១យួរ និងថវិកាចំនួន ៥០,០០០រៀល ព្រមទាំងឧបត្ថម្ភប៉ុស្តិ៍នគរបាល ឃុំគោកត្រប់ចំនួន ១២០,០០០រៀល និងឧបត្ថម្ភដល់ឃុំគោកត្រប់ថវិកាចំនួន ១លានរៀល។

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **ហ៊ុន ម៉ានី** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មការទី៧ នៃរដ្ឋសភា និងជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា និងលោកជំទាវ **យឹម ឆៃលីន** បានអញ្ជើញនាំយកអំណោយជាគ្រឿងឧបភោគបរិភោគជាមួយថវិកាមួយចំនួនប្រគល់ជូនរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីផ្តល់ជូនទៅឲ្យបងប្អូនប្រជាការពារខណ្ឌ និងសង្កាត់ទាំង១០៥ ទូទាំងរាជធានីភ្នំពេញ ដើម្បីសម្រួលដោះស្រាយការលំបាក។

ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ជាម យ៉េអ** តំណាងរាស្ត្រមណ្ឌលព្រៃវែង បានអញ្ជើញចុះពិនិត្យតាមដានសកម្មភាពនៃការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ជូនប្រជាពលរដ្ឋស្របតាមគោលនយោបាយ និងការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា និងបានជួបលើកទឹកចិត្តដល់បងប្អូនក្រុមគ្រូពេទ្យ បងៗរដ្ឋបាលភូមិ-ឃុំ និងបងប្អូនយុវជន ដើម្បីជំរុញឲ្យមានការខិតខំប្រឹងប្រែងបន្ថែមទៀតនៅក្នុងសកម្មភាពផ្តល់វ៉ាក់សាំងការពារកូវីដ១៩នៅក្នុងស្រុកស៊ីធរកណ្តាល។ ឯកឧត្តមក៏បាននាំយក សម្ភារៈ និងថវិកាមួយចំនួនចូលរួមឧបត្ថម្ភដល់ក្រុមគ្រូពេទ្យចាក់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ផងដែរ។

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **ជាវ តាយ** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តកំពត និងជាប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជាខេត្តកំពត អញ្ជើញចុះសួរ-សុខទុក្ខ និងចែកអំណោយដល់ប្រជាពលរដ្ឋងាយរងគ្រោះ និងរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ចំនួន១៥៣គ្រួសារ មកពីឃុំចំនួន១៣ ក្នុងស្រុកកំពង់ត្រាច ខេត្តកំពត។ ឯកឧត្តមបានពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពី**សម្តេចតេជោនាយករដ្ឋមន្ត្រី** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលជានិច្চកាលសម្តេចទាំងទ្វេ តែងតែគិតគូរខ្ពស់ពីសុខទុក្ខ និងមានការដោះស្រាយបញ្ហាប្រឈមនានា ជូនបងប្អូនប្រជាពលរដ្ឋដោយមិនដែលទុកចោលឲ្យប្រជាពលរដ្ឋណាម្នាក់ស្លាប់ដោយអត់ស្បៀងអាហារនិងមិនមានការដោះស្រាយនោះឡើយ។

សកម្មភាពសមាជិករដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **ស្វាយ សំអ៊ាង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ឯកឧត្តម **ម៉ែន ឌុយ** ប្រធានក្រុមប្រឹក្សាខេត្ត អមដំណើរដោយលោក អភិបាលរងខេត្ត លោកមេបញ្ជាការកងកម្លាំងប្រដាប់អាវុធទាំងបី ថ្នាក់ដឹកនាំមន្ទីរអង្គភាពពាក់ព័ន្ធ និងអាជ្ញាធរក្រុង បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រឆាំងនឹងជំងឺកូវីដ-១៩ ផ្តល់ជូនប្រជាពលរដ្ឋចំនួន ១៣៥គ្រួសារ រស់នៅតំបន់បិទខ្ទប់បណ្តោះអាសន្នមួយផ្នែក នៅក្រោយផ្សារសែនមនោរម្យ ស្ថិតនៅភូមិចំបក់ និងភូមិកណ្តាល ក្នុងសង្កាត់ ស្ពានមានជ័យ ក្រុងសែនមនោរម្យ ដែលមានប្រជាពលរដ្ឋវិជ្ជមានកូវីដ-១៩ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ។

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **ង៉ា ថន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តក្រចេះ បានដឹកនាំក្រុមការងារចម្រុះខេត្ត និងក្រុមគ្រូពេទ្យបានចុះរៀបចំដាក់ទីតាំងនៅមុខផ្សារសាមគ្គីក្រុងក្រចេះ ប្រមូលអាជីវករលក់ដូរក្នុងផ្សារទាំងអស់មកទទួលការយកសំណាក ធ្វើតេស្តរហ័សរកមេរោគកូវីដ-១៩ ដើម្បីអស់មានការមន្ទិលសង្ស័យ និងដើម្បីសុខសុវត្ថិភាព សុខភាព និងដើម្បីកាត់ផ្តាច់ចរន្តនៃការចម្លងមេរោគកូវីដ-១៩ ពីម្នាក់ទៅម្នាក់ ទៅលើបងប្អូនអាជីវករលក់ដូរក្នុងផ្សារសាមគ្គីក្រុងក្រចេះ។

ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១ លោកជំទាវ **បាន ស្រីមុំ** សមាជិកាគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិនដឹកនាំមន្ត្រីរាជការនិងក្រុមការងារអញ្ជើញចុះសំណេះសំណាលសួរសុខទុក្ខ និងជួយទិញបន្លែបង្ការរបស់ប្រជាកសិករ ដែលកំពុងជួបបញ្ហាទីផ្សារក្នុងអំឡុងវិបត្តិកូវីដ-១៩ ស្ថិតនៅភូមិបាយសី ឃុំស្នឹងត្រង់ ស្រុកសាលាក្រៅ និង ភូមិវាលវង់ សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន ដើម្បីយកមកធ្វើម្ហូបអាហារសម្រាប់ពលករកំពុងធ្វើចត្តាឡីស័ក និងព្យាបាលជម្ងឺកូវីដ-១៩ តាមមណ្ឌលនានា ក្នុងខេត្ត។ លោកជំទាវបានជំរុញដល់បងប្អូនប្រជាកសិករឱ្យខិតខំចិញ្ចឹមសត្វ និងដាំដុះបន្លែបង្ការសិរីរាង្គ តាមបែបធម្មជាតិ និងតម្រូវតាមទីផ្សារ ដើម្បីលើកកំពស់ជីវភាពក្នុងអំឡុងវិបត្តិកូវីដ-១៩។

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **អ៊ុំ រាត្រី** អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ អញ្ជើញបន្តនាំយកផ្លែមៀន ជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជូនពលករធ្វើចត្តាឡីស័ក និងមណ្ឌលព្យាបាលនៅមណ្ឌលធ្វើចត្តាឡីស័កស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **អ៊ូច តា** អភិបាលនៃគណៈអភិបាលខេត្តតាកែវ បានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយប្រគល់បងប្អូនប្រជាពលរដ្ឋ ១០០គ្រួសារ ស្ថិតនៅក្នុងតំបន់បិទខ្ទប់ ភូមិគោកអង្គង់ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស។ ឯកឧត្តមអំពាវនាវដល់ប្រជាពលរដ្ឋថា បើទោះបីជា បងប្អូនបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩រួចហើយ សូមបងប្អូនទាំងអស់ ត្រូវតែបន្តអនុវត្តនូវវិធានសុខាភិបាល **«៣ការពារ និង៣កុំ»** ដើម្បីចូលរួមចំណែកកាត់ផ្តាច់ខ្សែចម្លង និងជៀសឲ្យផុតពីការឆ្លងរាលដាល នៃជម្ងឺដ៏កាចសាហាវនេះ។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២១ ផ្នែកព័ត៌មាន និងបណ្តាញផ្សព្វផ្សាយសង្គម នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ដឹកនាំដោយឯកឧត្តម **ប៉ែន ពោធិ៍សា** សមាជិកគណៈកម្មាធិការកណ្តាល និងជាប្រធានផ្នែកព័ត៌មាន និងបណ្តាញផ្សព្វផ្សាយសង្គម នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានដឹកនាំកិច្ចប្រជុំ ដើម្បីកំណត់ផែនការសកម្មភាពរបស់យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាលឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ ឆ្នាំ២០២២ ក្រោមអធិបតីភាព លោកជំទាវ **ហេង សំអូន** សមាជិកគណៈកម្មាធិការកណ្តាល និងជាអនុប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ដែលមានការចូលរួមពីប្រធានតាមបណ្តាក្រុម នៃផ្នែកព័ត៌មាន និងបណ្តាញផ្សព្វផ្សាយសង្គម នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ព្រមទាំងសមាជិក សមាជិកា ជាច្រើនរូបទៀត តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយ ផ្ទាល់(Zoom Meeting)។

ឯកឧត្តម **ឃួត ហាក់** សមាជិកគណៈកម្មាធិការកណ្តាល សមាជិកគណៈអចិន្ត្រៃយ៍យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារវៀបចំអង្គការចាត់តាំងយុវជនគណបក្សប្រចាំទីបអឺរ៉ុបបាននាំយកអំណោយជាម៉ាស់និងឧបករណ៍តេស្តរហ័ស ជូនខេត្តមានដូចជា៖

- ខេត្តកំពង់ចាម ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១ បានប្រគល់អំណោយជាម៉ាស់ចំនួន ១០ ០០០ ម៉ាស់ និងឧបករណ៍តេស្តរហ័ស ចំនួន ១ ០០០ ជូនឯកឧត្តម **អ៊ុន ចាន់ដា** ប្រធានយុវជនគណបក្សប្រជាជនកម្ពុជាខេត្តកំពងចាម
- ខេត្តតាកែវ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១ បានប្រគល់អំណោយជាម៉ាស់ចំនួន ៦០ ០០០ ម៉ាស់ និងឧបករណ៍តេស្តរហ័ស ចំនួន ៥០០ ជូន ឯកឧត្តម **អ៊ូច តា** ប្រធានយុវជនគណបក្សប្រជាជនកម្ពុជាខេត្តតាកែវ។



ថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ២០២១ ឯកឧត្តម **គីម រិទ្ធី** សមាជិកគណៈកម្មាធិការកណ្តាល និងជាប្រធានផ្នែកទំនាក់ទំនងនិងសហប្រតិបត្តិការជាតិ-អន្តរជាតិ នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានអញ្ជើញដឹកនាំកិច្ចប្រជុំដើម្បីផ្សព្វផ្សាយផែនការសកម្មភាព និងជំនួយស្មារតីសម្រាប់ការអនុវត្តផែនការសកម្មភាព របស់យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ជូនថ្នាក់ដឹកនាំ សមាជិក និងក្រុមជំនួយការសរុបចំនួន ១០០នាក់ តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់(Zoom Meeting)។



ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ហេង សួរ** សមាជិកគណៈកម្មាធិការកណ្តាល និងជាប្រធានផ្នែករាជធានី ខេត្ត នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល រួមជាមួយ ឯកឧត្តមប្រធាន ផ្នែកទាំង៦ រួមមាន៖ ១.ផ្នែកចាត់តាំង ២.ផ្នែកផែនការ យុទ្ធសាស្ត្រ ៣.ផ្នែកក្រៅប្រព័ន្ធ ៤.ផ្នែកព័ត៌មាន និងបណ្តាញផ្សព្វផ្សាយសង្គម ៥.ផ្នែកបណ្តុះបណ្តាល និងទី៦.ផ្នែកឃោសនាអប់រំនៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានរៀបចំកិច្ចប្រជុំពិភាក្សាការងារ ដើម្បីចែករំលែកនូវព័ត៌មាន និងបទពិសោធន៍ជាពិសេសការភ្ជាប់បាននូវសំណូមពរបញ្ហាប្រឈម និងរបៀបរបបការងាររបស់ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជារាជធានី ខេត្ត ដើម្បីបន្តការអនុវត្តការងារឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ជាមួយប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជារាជធានី ខេត្ត សរុបចំនួន ២៣០នាក់ តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេង ដោយផ្ទាល់(Zoom Meeting)។



ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **យស ចាន់ត្ថា** សមាជិកគណៈកម្មាធិការកណ្តាល និងជាប្រធានផ្នែកបណ្តុះបណ្តាល នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានដឹកនាំកិច្ចប្រជុំដើម្បីផ្សព្វផ្សាយផែនការសកម្មភាព និងជំនួយស្មារតីសម្រាប់ការអនុវត្តផែនការសកម្មភាព របស់យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាលឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ និងផ្សព្វផ្សាយ ជូនសមាជិក សមាជិកាផ្នែក វាគ្មិន ក្រុមគ្រូឧទ្ទេស-គ្រូជំនួយ និងប្រធាន អនុប្រធានក្រុមជំនាញចំណុះផ្នែកបណ្តុះបណ្តាល នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល សរុបចំនួន ៣៥នាក់ តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់(Zoom Meeting)។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ហ៊ែល ចំរើន** ប្រធានក្រុមបូកសរុប នៃផ្នែកផែនការយុទ្ធសាស្ត្រ នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានដឹកនាំកិច្ចប្រជុំដើម្បីសំណេះសំណាល និងរៀបចំបែងចែកសមាសភាពទៅតាមការទទួលខុសត្រូវនីមួយៗ របស់ក្រុមបូកសរុប នៃផ្នែកផែនការយុទ្ធសាស្ត្រ ក្រោមអធិបតីភាព ឯកឧត្តម **ឃុត ចាន់ដារ៉ា** ប្រធានផ្នែកផែនការយុទ្ធសាស្ត្រ នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ដោយមានអ្នកចូលរួមសរុបចំនួន ៥០នាក់ តាមរយៈ ប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់(Zoom Meeting)។

ថ្ងៃទី៧ និងថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ លោក **ហោ សេរីវុឌ្ឍន៍** សមាជិកគណៈអចិន្ត្រៃយ៍ និងជាប្រធានផ្នែកក្រៅប្រព័ន្ធ នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល តំណាងឯកឧត្តម **ហ៊ុន ម៉ាណែត** និងលោកជំទាវ បាននាំយកអំណោយ តាមរយៈផ្នែកក្រៅប្រព័ន្ធ នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ជូនខេត្តមានដូចជា៖ ខេត្តឧត្តរមានជ័យ ប្រគល់អំណោយជាម៉ាស់ចំនួន ១០ ៥០០ ម៉ាស់ ជូន ឯកឧត្តម **ប៉ែន កុសល្យ** ប្រធានយុវជនគណបក្សប្រជាជនកម្ពុជាខេត្តឧត្តរមានជ័យ, ខេត្តសៀមរាប ប្រគល់អំណោយជាម៉ាស់ចំនួន ១០ ០០០ ម៉ាស់ ជូន ឯកឧត្តម **គុជ លីណា** អនុប្រធានយុវជនគណបក្សប្រជាជនកម្ពុជាខេត្តសៀមរាប, ខេត្តព្រះវិហារ ប្រគល់អំណោយជាទឹកសុទ្ធ ១០០ កេស និង ម៉ាស់ចំនួន ១០ ០០០ ម៉ាស់ ជូន ឯកឧត្តម **អ៊ុក គីមសាន** ប្រធានយុវជនគណបក្សប្រជាជនកម្ពុជាខេត្តព្រះវិហារ។

ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ហាក់ សុខមករា** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តត្បូងឃ្មុំ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីប្រកាស តែងតាំងសមាសភាពក្រុមការងារយុវជនគណបក្ស ក្នុងរចនាសម្ព័ន្ធស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងបានផ្សព្វផ្សាយផែនការសកម្មភាព របស់ក្រុមការងារយុវជនគណបក្សខេត្ត ឆ្ពោះទៅកាន់ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ខាងមុខ ដើម្បីធានាបាននូវជ្រើសរើសបានល្អរបស់គណបក្សប្រជាជនកម្ពុជា ដែលមានអ្នកចូលរួមចំនួន ២៣៩នាក់ នៅទីស្នាក់គណបក្សប្រជាជនកម្ពុជាខេត្តត្បូងឃ្មុំ។

ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **តុន សារពេជ្រ** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តកំពត បានដឹកនាំកិច្ចប្រជុំក្រុមការងារយុវជនគណបក្ស ក្នុងត្រីមាសទី៣ ឆមាសទី២ ឆ្នាំ២០២១ ដើម្បីកែតម្រូវរបាយការណ៍ដែលបានអនុវត្តរួចឱ្យកាន់តែល្អ និងដាក់ចេញនូវ គោលការណ៍ ថ្មី ដោយមានការចូលរួមពីសមាជិក សមាជិកាក្រុមការងារយុវជនគណបក្សប្រជាជនខេត្តកំពត នៅទីស្នាក់គណបក្សប្រជាជនកម្ពុជាខេត្តកំពត។



ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **ហេង សុខណាង** សមាជិកគណៈកម្មាធិការកណ្តាល សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តស្វាយរៀង បានអញ្ជើញដឹកនាំកិច្ចប្រជុំស្តីពីការរៀបចំរចនាសម្ព័ន្ធក្រុមការងារយុវជនគណបក្សខេត្ត និងផ្សព្វផ្សាយផែនការសកម្មភាព ឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកា សរុបចំនួន ២៧នាក់ តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់(Zoom Meeting)។

ថ្ងៃទី០៥ ខែ សីហា ឆ្នាំ២០២១ ឯកឧត្តម **ង៉ា ថន** សមាជិកគណៈ-កម្មាធិការកណ្តាល សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តក្រចេះ បានអញ្ជើញដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយផែនការសកម្មភាពរបស់យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ និងរៀបចំរចនាសម្ព័ន្ធ ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា ចំណុះក្រុមការងារយុវជនគណបក្សថ្នាក់ ស្រុក/ក្រុង ដែលនៅសល់ នៅសាលប្រជុំទីស្នាក់ការគណបក្សខេត្តក្រចេះ។

សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

រយៈពេល ៧ខែ ដើមឆ្នាំ៖

❋ ទំហំពាណិជ្ជកម្មកម្ពុជា-អាមេរិក សម្រេចបានជាង ៤.០៧៧ លានដុល្លារ កើនឡើង ៣៧,៨៤% បើប្រៀបធៀបនឹងរយៈពេលដូចគ្នា នៅឆ្នាំ២០២០ មានចំនួន ២.៩៥៧លានដុល្លារ។ កម្ពុជា បាននាំចេញទៅអាមេរិកក្នុងទំហំទឹកប្រាក់ជាង ៣.៨៦៧លានដុល្លារ ខណៈការនាំចូលពីអាមេរិកវិញ ក្នុងទំហំទឹកប្រាក់ជាង ២០៩លានដុល្លារ។ គួសបញ្ជាក់ថារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា-អាមេរិកមានកំណើនគួរឲ្យកត់សម្គាល់៖ឆ្នាំ២០១៥មានទឹកប្រាក់ ២.៣៦៥លានដុល្លារ, ឆ្នាំ២០១៦ ហាក់ថមថយបន្តិច មានទឹកប្រាក់ ២.៣២០លានដុល្លារ,ឆ្នាំ២០១៧មានទឹកប្រាក់២.៦០៥លានដុល្លារ, ឆ្នាំ២០១៨ មានទឹកប្រាក់ ៣.៤៣៨ លានដុល្លារ, ឆ្នាំ២០១៩ មានទឹកប្រាក់ជាង ៤.៧១៣លានដុល្លារ និងឆ្នាំ២០២០ មានទឹកប្រាក់ជាង ៥.៥០៩លានដុល្លារ។

❋ ពាណិជ្ជកម្មកម្ពុជា កូរ៉េខាងត្បូង មានទំហំទឹកប្រាក់ ៥៥២,១ លានដុល្លារ កើនឡើង១០,៦% ធៀបរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះកម្ពុជានាំចេញទៅកូរ៉េខាងត្បូងមានតម្លៃ ១៨៨,២លានដុល្លារ កើនឡើង ០,២% ពីចំនួន១៨៧,៨លានដុល្លារ ឯការនាំចូលពីកូរ៉េខាងត្បូងមានតម្លៃ៣៦៤លានដុល្លារកើនឡើង១៧,២%ពីចំនួន៣១០,៩៤លានដុល្លារ ធៀបរយៈពេលដូចគ្នាឆ្នាំ២០២០។

❋ តាមរបាយការណ៍របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ បានឲ្យដឹងថា គិតរហូតមកដល់ពាក់កណ្តាលខែសីហា នេះ កម្ពុជាមានត្រាក់ទ័រសរុបសម្រាប់បម្រើការ ការងារ កសិកម្ម ចំនួន ៣២.០៩៤ គ្រឿង ។ ក្រៅពីត្រាក់ទ័រ កម្ពុជានៅមាន គោយន្ត ៤៩៨.១១៩គ្រឿង ម៉ាស៊ីនច្រូតស្រូវ ៦.៧៩២គ្រឿង ម៉ាស៊ីនបូមទឹក ៤០២.៧៩៦ គ្រឿង ម៉ាស៊ីនបោកស្រូវ ១២.៥២៥ គ្រឿង និងម៉ាស៊ីន កិនស្រូវ ៤២.៩៥៤ គ្រឿងបន្ថែមទៀតសម្រាប់ជួយការងារធ្វើស្រែ ចម្ការផ្សេងៗ ។

❋ កម្ពុជារកចំណូលបានជិត ២,៥ពាន់លានដុល្លារ ពីការ នាំចេញកសិផលសំខាន់ៗ ប្រមាណជិត ១០០មុខ ដោយមិនរាប់បញ្ចូនកសិផលស្រូវ-អង្ករ។ ផលិតផលដែលនាំចេញនោះ មានទម្ងន់ ៣.៤៣២.៦០១,០៨ តោនកើនឡើង ១.១៦៨.៦៨៦,៨៧តោន ស្មើនឹង ៥១,៦២% បើធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២០ ។ កសិផលសំខាន់ៗ ដែលកម្ពុជានាំចេញក្នុងនោះរួមមាន៖ ចំណិត ដំឡូងមីក្រៀម មានចំនួន ១.២៥៤.០០៣,១២តោន (កើនឡើង ចំនួន ១៤,២២%) , ដំឡូងមីស្រស់ មានចំនួន ៣៩៦.៣០០តោន (ថយចុះចំនួន -៨,៦៤%), ម៉្សៅដំឡូងមី មានចំនួន ១៨.៤៦៥, ០៤តោន (កើនឡើងចំនួន ២២,៤៣%) , កាកសំណល់ដំឡូងមី មានចំនួន ៤.៩០៨តោន (ថយចុះចំនួន-៣៦,១១%), គ្រាប់ ស្វាយចន្ទី មានចំនួន ៨៦៦ .២០៧,៧៧តោន (កើនឡើងចំនួន ៣៤៥,២៩%), គ្រាប់ពោត មានចំនួន ១៤៦.៣០៤,១៩តោន (កើនឡើងចំនួន ១,០៩%),គ្រាប់សណ្តែកបាយមានចំនួន ២១.២៣០តោន (កើនឡើងចំនួន ៥៤៧,៣៣%),ផ្លែចេកស្រស់មានចំនួន ២៧០.២២១, ៦៨តោន (កើនឡើងចំនួន ៦១,០៨%) , ផ្លែក្រូចថ្លុង មានចំនួន ២៧.៤១៨,៤៤តោន (កើនឡើងចំនួន ៩០,៤១%) , ផ្លែស្វាយស្រស់ មានចំនួន ១៦១.២២៨,៥៥តោន (កើនឡើងចំនួន ២៤៧,៩២%), ម្រេចមានចំនួន ២២.៥៨០,៦៨តោន (កើនឡើងចំនួន ៥៥៨,១៩%) ព្រមទាំងផលិតផលមួយ ចំនួនទៀត ។

I- លទ្ធផលការងារបង្កបង្កើនផលដំណាំរដូវស្សាឆ្នាំ២០២១ គិតមកត្រឹមថ្ងៃទី១៩ ខែសីហា

១- ការងារដាំដុះ ៖

ក- លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ២.៧០១.១៨៩ហ.ត, ក្នុងនោះភ្ជួររាស់ដោយគោក្របីចំនួន ១៦.២៦១ហ.ត ស្មើនឹង ០,៦០% និងដោយគ្រឿងយន្តចំនួន ២.៦៨៤.៩២៨ហ.ត ស្មើនឹង ៩៩,៤០% លើសឆ្នាំមុន ១២៩.៤៤៩ហ.ត ។

ខ- លទ្ធផលស្ទូងនិងព្រោះសម្រេចបានចំនួន ២.៦៥៨.៧៥៦ ហ.ត ស្មើនឹង ១០១,៩០% នៃផែនការ ២.៦០៩.០៦៥ហ.តលើសឆ្នាំមុន ២០៦.៨៧០ហ.ត និងស្រូវតាមប្រភេទរួមមាន៖ ស្រូវស្រាល ចំនួន ៨៩០.៦៤៥ហ.ត លើសឆ្នាំមុន ១៧៩.៦០០ហ.ត, ស្រូវ កណ្តាល ចំនួន ១.២៨៩.៧៦២ហ.ត លើសឆ្នាំមុន ២៧.០៧៦ហ.ត, ស្រូវធ្ងន់ ចំនួន ៤៣៦.០៩១ហ.ត លើសឆ្នាំមុន ៩.៨៦៥ហ.ត, ស្រូវ ចម្ការចំនួន ១៩.៦១២ហ.ត លើសឆ្នាំមុន ១.១១៦ហ.ត, ស្រូវឡើងទឹកចំនួន ២២.៦៤៦ហ.ត តិចជាងឆ្នាំមុន ១០.៧៨៧ហ.ត ។

២- ល្បឿនការងារប្រមូលផលស្រូវស្រាលដើមរដូវស្សាឆ្នាំ២០២១ ៖

ការងារប្រមូលផល ស្រូវស្រាលដើមរដូវសម្រេចបានចំនួន ៣០២.៣៣៧ហ.ត លើផ្ទៃដីអនុវត្តស្រូវស្រាលសរុប ៨៩០.៦៤៥ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ១.២៦៧.៧៩១តោន លើសឆ្នាំមុន ៧៨៩.១៥១តោន ។ ទិន្នផលគិតជាមធ្យម ៤,១៩៣ តោន/ហ.ត ។

II-ល្បឿនការងារបង្កបង្កើនផលដំណាំសាកវប្បកម្មនិងដំណាំឧស្សាហកម្ម រដូវស្សាឆ្នាំ២០២១

ក- ផ្ទៃដីដំណាំសាកវប្បកម្ម (ពោតស ដំឡូងជ្វា បន្លែគ្រប់មុខ ម្ទេសឌីឡឹក) អនុវត្តបានចំនួន ៥១.៥៣៧ហ.ត ស្មើនឹង ៩៥,៦៦ ភាគរយ នៃផែនការ ៥៣.៦៨៦ហ.ត តិចជាងឆ្នាំមុន ១៦៥ហ.ត ។

ខ- ផ្ទៃដីដំណាំឧស្សាហកម្ម (ពោតក្រហម ដំឡូងមី សណ្តែកបាយ សណ្តែកដី សណ្តែកសៀង ល្ង អំពៅ ក្រចៅ ឈូក) អនុវត្តបានចំនួន ៧៦៦.៣៧៥ហ.ត ស្មើនឹង ៩៣,៤៦ភាគរយ នៃផែនការ ៨១៩.៩៨៩ហ.ត លើសឆ្នាំមុន ៧.៩៤៤ហ.ត ៕

កម្ពុជាបន្តពុះពារសម្រេចឲ្យបានឆ្ងាចក្នុងវិស័យនៃការអភិវឌ្ឍរបស់ខ្លួន

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានរៀបចំឡើងក្នុងខណៈដែលប្រទេសជាតិកំពុងស្ថិតនៅក្នុងស្ថានភាពលំបាកនៃវិបត្តិជំងឺកូវីដ-១៩ ហើយជំនន់ទឹកភ្លៀងឆ្នាំ២០២០ ក៏បានបង្កើនថែមទៀតនូវសម្ពាធនៃតម្រូវការចំណាយថវិកាឆ្នាំ២០២១ ។ ថវិកាឆ្នាំ២០២១ អាចចាត់ទុកជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាពក្នុងការរក្សាលំនឹងសេដ្ឋកិច្ច និងជីវភាពប្រជាជនទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ដ៏កាចសាហាវ ព្រមទាំងបម្រើដល់ការស្តារសេដ្ឋកិច្ច និងជំរុញកំណើនជាបណ្តើរៗឡើងវិញ។

តាមការព្យាករណ៍ពីដើមឆ្នាំកំណើនសេដ្ឋកិច្ចកម្ពុជារំពឹងសម្រេចបាន ៤% ប៉ុន្តែផ្អែកតាមការវាយតម្លៃពាក់កណ្តាលឆ្នាំ២០២១ ដោយសារការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុង «ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ» សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថា នឹងមានកំណើន ២,៤% គឺទាបជាងការព្យាករណ៍កាលពីដើមឆ្នាំ។ វិស័យឧស្សាហកម្មត្រូវបានប៉ាន់ស្មានថានឹងមានកំណើនថមថយមកត្រឹមអត្រា៥,៧%ក្នុងឆ្នាំ២០២១ បើធៀបនឹងកំណើនក្នុងអត្រា៥,៩% ដែលត្រូវបានព្យាករណ៍ពីដើមឆ្នាំ ដោយសារកំណើនថមថយនៃអនុវិស័យសំណង់ ខណៈដែលអនុវិស័យកាត់ដេរអាចសម្រេចបានកំណើនដូចការរំពឹងទុក និងអនុវិស័យកម្មន្តសាល មិនមែនកាត់ដេរមានកំណើនខ្ពស់ជាងការរំពឹងទុក។ វិស័យសេវាកម្មត្រូវបានប៉ាន់ស្មានថានឹងមានកំណើន ទាបជាងការព្យាករណ៍កាលដើមឆ្នាំ ដោយសារការបន្តធ្លាក់ចុះនៃអនុវិស័យធនាគារ និងភោជនីយដ្ឋាន ការថមថយកំណើននៃអនុវិស័យលក់ដុំ-រាយ និងអចលនទ្រព្យ ខណៈដែលអនុវិស័យដឹកជញ្ជូននិងគមនាគមន៍ត្រូវបានប៉ាន់ស្មានថាមានកំណើនល្អប្រសើរជាងការរំពឹងទុក។ វិស័យកសិកម្មត្រូវបានវាយតម្លៃថានឹងកើនឡើងក្នុងរង្វង់ ១,៤%ក្នុងឆ្នាំ២០២១ ពីកំណើន ១,៣% ដែលត្រូវព្យាករណ៍កាលពីដើមឆ្នាំ ដែលឆ្លុះបញ្ចាំងតាមរយៈនិន្នាការល្អនៃអនុវិស័យដំណាំ និងអនុវិស័យចិញ្ចឹមសត្វ ខណៈអនុវិស័យនេសាទនឹងបន្តកំណើនទាប។ ការអនុវត្តចំណូលឆមាសទី១ ឆ្នាំ២០២១ សម្រេចបានស្មើនឹង៤៥,១% នៃច្បាប់ហិរញ្ញវត្ថុគឺខ្ពស់ជាង ៨,១ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ដែលអនុវត្តបាន៣៧,០%នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់កើនឡើង៥,៤%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ។ការអនុវត្តចំណាយឆមាសទី១ឆ្នាំ២០២១ ចំណាយថ្នាក់ជាតិអនុវត្តបានស្មើនឹង៤១,៣% នៃច្បាប់ហិរញ្ញវត្ថុគឺមានសន្សុះដូចគ្នាធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០ ដែលអនុវត្តបាន៤១,៣% នៃច្បាប់ហិរញ្ញវត្ថុ,បើគិតចំណាយជាសាច់ប្រាក់ថយចុះ0,១%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ។ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តបានស្មើនឹង៣៥,៩%នៃច្បាប់ហិរញ្ញវត្ថុមានសន្សុះលឿនជាង ១០,៣ពិន្ទុភាគរយ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ដែលអនុវត្តបាន ២៥,៦% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ៨,៦%ធៀបនឹងរយៈ ពេលដូចគ្នាឆ្នាំ២០២០ ។ ការអនុវត្តថវិកាឆមាសទី១ ឆ្នាំ២០២១ នេះ បានឆ្លុះបញ្ចាំងអំពីលទ្ធផល និងប្រសិទ្ធភាពនៃការកៀរគរចំណូលតាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ។ ជាមួយគ្នានេះ ប្រសិទ្ធនៃប្រតិបត្តិការចំណាយបានធ្វើឡើងតាមរយៈការតម្រង់ការចាយឲ្យចំមុខ និងមិនខ្ជះខ្ជាយដែលធ្វើឲ្យរាជរដ្ឋាភិបាលមានលទ្ធភាពឆ្លើយតបបានកាន់តែមានប្រសិទ្ធភាពទៅនឹងបណ្តាតម្រូវការជាអាទិភាពនានា ជាពិសេសការអនុវត្តក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២១។

តាមការគ្រោងទុកពីដើមឆ្នាំ២០២១ រាជរដ្ឋាភិបាលបានដាក់ចេញកញ្ចប់ថវិកាអន្តរាគមន៍ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ក្នុងទំហំប្រមាណ៧១៩លានដុល្លារ ប៉ុន្តែដោយសារព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ ទំហំនៃថវិកាចំណាយអន្តរាគមន៍ក្នុងឆ្នាំ២០២១ អាចឡើងដល់១.៤៥៤លានដុល្លារ។ ការកើនឡើងយ៉ាងគំហុកនៃបន្ទុកចំណាយលើផ្នែកសុខាភិបាល និងសង្គម នឹងធ្វើឲ្យឱនភាពថវិកាឆ្នាំ២០២១ រីកធំដល់ទៅ១១,០៩% នៃផ.ស.ស ខ្ពស់ជាងការគ្រោងក្នុងច្បាប់ថវិកាប្រមាណជិត២ពិន្ទុភាគរយ។ ទោះយ៉ាងណាការីកធំនៃឱនភាពថវិកានេះមិនទាន់ចោទជាបញ្ហាធំដុំសម្រាប់រាជរដ្ឋាភិបាលទេ ដោយសារតម្រូវការថវិកាបន្ថែមនេះ នឹងត្រូវបំពេញមកវិញតាមរយៈការបញ្ចេញបន្ថែមនៃផែនការប្រាក់សន្សំរាជរដ្ឋាភិបាលដែលនឹងអនុញ្ញាតឲ្យកម្ពុជាបន្តគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួនប្រកបដោយទំនុកចិត្ត ភាពរឹងមាំ និងភាពជាម្ចាស់ការខ្ពស់។ សម្រាប់ឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជារំពឹងថាសម្រេចបានក្នុងអត្រា៤,៨%ដោយសារការសម្របខ្លួនបានទៅនឹងប្រក្រតីភាពថ្មី ភាពធូរស្រាលនៃជំងឺកូវីដ-១៩ ដែលនឹងជួយជំរុញការងើបឡើងវិញនៃវិស័យមួយចំនួន និងការលំហូរទុនវិនិយោគ។

កម្ពុជាអាចនឹងជួបហានិភ័យពីកត្តាខាងក្រៅប្រទេស និងបញ្ហាប្រឈមមួយចំនួននៅក្នុងប្រទេសដែលតម្រូវឲ្យរាជរដ្ឋាភិបាលដាក់ចេញវិធានការមុតស្រួច និងទាន់ពេលវេលា ដើម្បីបញ្ចៀស និងបន្ធូរបន្ថយសម្ពាធហានិភ័យ និងបញ្ហាប្រឈមនានាដែលអាចកើតឡើងជាយថាហេតុតាមរយៈការដាក់ចេញ និងអនុវត្តវិធានការគោលនយោបាយដែលឆ្លើយតបទាំងក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច និងទាំងក្នុងផ្នែកហិរញ្ញវត្ថុសាធារណៈ។

ទោះបីការអនុវត្តថវិកាឆ្នាំ២០២១ ជួបបញ្ហាប្រឈមមួយចំនួនក្តី ប៉ុន្តែក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី និងស្មារតីនៃការបន្តចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ កម្ពុជានៅតែបន្តពុះពារសម្រេចឲ្យបាននូវចក្ខុវិស័យនៃការអភិវឌ្ឍវែងឆ្ងាយរបស់ខ្លួន៕

អនុគ្គរភាពទឹក: គម្រោងអាទិភាពចំនួន២៥ បាននិងកំពុងអនុវត្តតាមផែនការគ្រោងទុក

ការដ្ឋានប្រឡាយរងទូកមាស កំពត

ជាផ្នែកមួយនៃនយោបាយអនុគ្គរភាពទឹករបស់ក្រសួងធនធានទឹក និងឧតុនិយម ក្នុងឆ្នាំ២០២១ នេះ ក្រសួងបានកំណត់នូវគម្រោងអាទិភាព មួយចំនួនដែលក្នុងនោះមាន៖ គម្រោងស្តារព្រែក,គម្រោងស្តារឡើងវិញ ប្រព័ន្ធធារាសាស្ត្រ, គម្រោងពង្រីកសក្តានុពលប្រព័ន្ធធារាសាស្ត្រ និង គម្រោងស្ថាបនាប្រព័ន្ធធារាសាស្ត្រថ្មី ។ បណ្តាគម្រោងទាំងនេះបាន និងកំពុងអនុវត្តទៅតាមផែនការកំណត់។

ទាក់ទងនឹងគម្រោងស្តារព្រែកគឺមានព្រែកចំនួន៦នៅក្នុងចំណោម ៤០ ត្រូវបានក្រសួងធនធានទឹក និងឧតុនិយមសម្រេចជ្រើសរើសជា ព្រែកអាទិភាព ដើម្បីស្តារឡើងវិញដោយប្រើប្រាស់ហិរញ្ញប្បទានរបស់ ទីភ្នាក់ងារបារាំង សម្រាប់ការអភិវឌ្ឍក្រោមកម្មវិធី ***ការគ្រប់គ្រងធនធានទឹក និងការផ្លាស់ប្តូរកសិកម្ម នៅប្រទេសកម្ពុជា*** (WAT4CAM) ដែលនឹងចាប់ផ្តើមអនុវត្តនៅចុងឆ្នាំ២០២១ នេះ។

ក្នុងឆ្នាំ២០២១នេះដែរ នាយកដ្ឋានវិស្វកម្មបានអនុវត្តការងារសាង សង់ជួសជុល និងស្តារប្រព័ន្ធ ធារាសាស្ត្រនៅតាមបណ្តារាជធានី-ខេត្ត ទូទាំងប្រទេសនូវគម្រោងអាទិភាព (គម្រោងតម្រូវការចាំបាច់) ចំនួន ២៥គម្រោង។ គិតត្រឹមដំណាច់ខែឧសភាកន្លងទៅនេះគម្រោងអាទិភាព មានចំនួន ២៥ គម្រោង ក្នុងនោះមាន៖ ការងារស្តារឡើងវិញប្រព័ន្ធ ធារាសាស្ត្រចំនួន ៤ គម្រោងរួមមាន៖ **ទី១**-ការងារស្តារឡើងវិញទំនប់ អាងទឹកគោអើត និងសាងសង់សំណង់សិល្បការស្ថិតនៅឃុំមេព្រីង ស្រុកបាធាយ ខេត្តកំពង់ចាម។ទំនប់អាងទឹកគោអើតប្រវែង ៣.៦០០ ម៉ែត្រ អាចស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ៧២ហ.ត ស្រូវប្រាំងចំនួន ៥៣៣ហ.ត ដំណាំរួមផ្សំ ១៥ហ.តនិងអ្នកទទួលផល ៩០០គ្រួសារ មានសមាជិក ៤.០៤៥នាក់។ការងារនេះសម្រេចបាន ៨០% **ទី២**-ការ ស្តារឡើងវិញទំនប់អាងទឹកអន្លង់ពួយ និងសាងសង់សំណង់សិល្បការ ស្ថិតនៅឃុំយុទ្ធសាមគ្គី ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺប្រវែង ១.៨០០ម៉ែត្រ និងប្រឡាយរងអូរតូចប្រវែង ២.៣០០ម៉ែត្រ ។ គម្រោងនេះអាច ស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ៤៨៧ហ.តស្រូវប្រាំងចំនួន ៧២ហ.ត ដំណាំរួមផ្សំ ១១ហ.ត និងផ្តល់ផលប្រយោជន៍ដល់ប្រជាជនចំនួន ៤៣១គ្រួសារ ដែលមានសមាជិក ១.៤៥៣នាក់។ការដ្ឋាននេះសម្រេច បាន ៧៥% **ទី៣**-ការងារសាងសង់បន្ថែមសំណង់សិល្បការនិងជួសជុល សំណង់បង្ហៀរ លើទំនប់អាងទឹកប្រមូលដុំ ស្ថិតនៅឃុំស្មោង ខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ គម្រោងនេះសម្រេចបាន៧0%ហើយ។ ការដ្ឋាននេះនៅពេលបញ្ចប់នឹងមានលទ្ធផលស្រោចស្រពផ្ទៃដីស្រូវ វស្សា ចំនួន ២១០ហ.ត ស្រូវប្រាំងចំនួន ១៤៧ហ.ត ដំណាំរួមផ្សំ ២ហ.ត និងប្រជាជនចំនួន ៣១២គ្រួសារ មានសមាជិក ៩៨៩នាក់នឹង ទទួល ផលពីគម្រោងនេះ **ទី៤**-ការងារស្តារឡើងវិញទំនប់អាងទឹកខ្ពបត្របែក និងសាងសង់សំណង់សិល្បការស្ថិតនៅឃុំអូរសារាយ ស្រុក ត្រាំកក់ ខេត្ត តាកែវ។ទំនប់អាងទឹកខ្ពបត្របែកមានប្រវែង ២.៦០០ម៉ែត្រ។ ការដ្ឋាន នេះសម្រេចបាន៦0%។ទំនប់នេះមានលទ្ធផលស្រោចស្រពផ្ទៃដីស្រូវ វស្សាចំនួន៣.៥៨0ហ.ត ស្រូវប្រាំងចំនួន៥២៦ហ.ត ដំណាំ រួមផ្សំ ចំនួន ៥0ហ.តនិងអ្នកទទួលផលចំនួន ៣.៧0៧គ្រួសារ ស្មើនឹង មនុស្សរាយ១៦.២៨៨នាក់ ។

ជាមួយគ្នានេះមាន គម្រោងអាទិភាពពង្រីកសក្តានុពលប្រព័ន្ធ ធារាសាស្ត្រចំនួន ៧ គម្រោងទៀតគឺ៖ **ទី១**-ការងារជីកប្រឡាយរង តាសុវណ្ណ និងសាងសង់សំណង់សិល្បការស្ថិតនៅឃុំកំពង់ព្រៀង ស្រុកសង្កែខេត្តបាត់ដំបង។ គម្រោងនេះសម្រេចបានជាង៧0% ហើយ។ ក្រោយបញ្ចប់ការដ្ឋាននេះមានលទ្ធផល ស្រោចស្រពផ្ទៃដីស្រូវវស្សា ចំនួន ១.៧៨៥ហ.ត ស្រូវប្រាំងចំនួន ៥៨0ហ.ត ដំណាំរួមផ្សំចំនួន ២0ហ.តនិងប្រជាជនទទួលផលចំនួន១.៣៩៩គ្រួសារ មានសមាជិក ៥.៤៧២នាក់។ **ទី២**-ការងារជីកប្រឡាយរងស្ទឹងទូកមាស សាងសង់ សំណង់សិល្បការស្ថិតនៅឃុំទូកមាសខាងលិចនិងឃុំទូកមាសខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត។ ប្រឡាយរងស្ទឹងទូកមាសប្រវែង ៤.000 ម៉ែត្រ សម្រេចបានជាង៧0%ហើយ។ប្រឡាយនេះអាចស្រោចស្រព ផ្ទៃដីស្រូវវស្សាចំនួន ១.២00ហ.ត ស្រូវប្រាំងចំនួន ១៥0ហ.ត ដំណាំរួមផ្សំចំនួន ២0ហ.តនិងប្រជាជនទទួលផលចំនួន ១.៤៩៨គ្រួសារ មានសមាជិក ៥.២៦៤នាក់ **ទី៣**-ការងារ ជីកព្រែកភ្នំល្ងៀង និងសាង-សង់សំណង់សិល្បការស្ថិតនៅឃុំស្តេចគង់ខាងជើង និងឃុំស្តេចគង់ ខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត ប្រវែង ៧.000ម៉ែត្រ។ព្រែក នេះអាចស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ១.0៥២ហ.ត ស្រូវប្រាំង ចំនួន ៤៥0ហ.ត ដំណាំរួមផ្សំចំនួន ៣0ហ.តនិងប្រជាជនទទួលផល ចំនួន ១.៣៥១គ្រួសារ មានសមាជិក ៦.៦១៥នាក់។ គម្រោងនេះ សម្រេចបាន ៧0% **ទី៤**-ការងារស្តារឡើងវិញទំនប់អាងទឹកស្វាយ តាយានស្ថិតនៅឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង មានប្រវែង ៤.0២0 ម៉ែត្រនិងមានលទ្ធផលស្រោចស្រពផ្ទៃដីស្រូវវស្សា ចំនួន២១៥ហ.តស្រូវប្រាំងចំនួន៣៨ហ.តដំណាំរួមផ្សំចំនួន១0ហ.ត គម្រោងនេះសម្រេចបាន៧៥%ហើយ។ប្រជាជនចំនួន ២៣២គ្រួសារ មានសមាជិក ៩៣៨នាក់នឹងទទួលផលពីទំនប់នេះ **ទី៥**-ការងារជីកអូរ ព្រៃឃ្មេសស្ថិតនៅឃុំព្រៃឃ្មេស ស្រុកមេសាង ខេត្តព្រៃវែង ប្រវែង ៧.000ម៉ែត្រ។ការដ្ឋាននេះក្រោយបញ្ចប់អាចស្រោចស្រពផ្ទៃដីស្រូវ វស្សាចំនួន៧៥0 ហ.តស្រូវប្រាំងចំនួន២១0ហ.តដំណាំរួមផ្សំចំនួន ១៥ហ.ត។ប្រជាជនចំនួន ៧៣0គ្រួសារ មានសមាជិក ៣.១៨៣នាក់ នឹងទទួលបានផលពីគម្រោងនេះ។ការដ្ឋាននេះសម្រេចបាន ៧0% **ទី៦**-ការងារប្រឡាយមេត្មោតទេរ ស្ថិតនៅឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ មានប្រវែង២.៣00ម៉ែត្រ។ ការដ្ឋាននេះសម្រេចបាន ជិត៧0%ហើយ។ ប្រឡាយនេះមានលទ្ធផលស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ៣៨៧ហ.ត ស្រូវប្រាំងចំនួន ១១0ហ.ត ដំណាំរួមផ្សំចំនួន ១0ហ.តនិងប្រជាជន

ចំនួន ៨២៨គ្រួសារ មានសមាជិក ៤.៤៥០នាក់នឹងទទួលផលពីប្រឡាយនេះ ទី៧-ការងារសាងសង់ទំនប់អាងទឹកអូរឃ្លង់ស្ថិតនៅឃុំរមេញ និងឃុំធ្លាប្រជុំ ស្រុកកោះអណ្តែតខេត្តតាកែវ ប្រវែង ៥.០៥០ម៉ែត្រ។ ការងារនេះសម្រេចបាន៧៥%។លទ្ធផលស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ៣៤៥ហ.ត ស្រូវប្រាំងចំនួន ១៤០ហ.ត ដំណាំរួមផ្សំចំនួន ២០ហ.ត និងប្រជាជនចំនួន ៤៣៤គ្រួសារ មានសមាជិក ២.១៤៧នាក់នឹងទទួលផលពីទំនប់នេះ។

ជាមួយគ្នានេះដែរ ក្រសួងធនធានទឹក និងឧតុនិយម ក៏មានគម្រោងអាទិភាពមួយទៀត គឺគម្រោងស្ថាបនាប្រព័ន្ធធារាសាស្ត្រថ្មីចំនួន ១៤ ក្នុងនោះមាន៖ **ទី១**-ការងារសាងសង់ទំនប់អាងទឹកជើងគ្រុះ និងសាងសង់សំណង់សិល្បការ ស្ថិតនៅក្នុងឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយ - មានជ័យប្រវែង ៣.០០០ម៉ែត្រ។ ការដ្ឋាននេះសម្រេចបាន៧៥%។ ទំនប់នេះមាន លទ្ធភាពស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ៧៨៧ហ.ត ស្រូវប្រាំងចំនួន ៣៥១ហ.ត ដំណាំរួមផ្សំចំនួន ១០ហ.តនិងប្រជាជនទទួលផលចំនួន ២.៥៧៧គ្រួសារ មានសមាជិក ៩.៣៥៣នាក់។ **ទី២**-ការងារជីកប្រឡាយមេស្រណាល និងសាងសង់សំណង់សិល្បការស្ថិតនៅឃុំសំបូរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។ការដ្ឋាននេះសម្រេចបាន៧០%។ ក្រោយបញ្ចប់លទ្ធភាពស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ១.៩១៨ហ.ត ស្រូវប្រាំងចំនួន ២០០ហ.ត ដំណាំរួមផ្សំចំនួន ១០ហ.ត និងប្រជាជន ទទួលផល១.១០២គ្រួសារ មានសមាជិក ៤.៨៨៤នាក់ **ទី៣**-ការងារសាងសង់សំណង់ស្ទាក់ទឹក ស្ទឹងមង្គលបុរីស្ថិតនៅក្នុងឃុំអូរដា និងឃុំតាក្រី ស្រុកកំរៀង ខេត្តបាត់ដំបង ប្រវែង៣៥០ម៉ែត្រ។ ការងារនេះសម្រេចបាន៦០%ហើយ។ ទំនប់នេះអាចស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ១.៨៥០ ហ.ត ស្រូវប្រាំងចំនួន ៣៦០ហ.ត ដំណាំរួមផ្សំចំនួន ៤៧០ហ.តនិងប្រជាជនទទួលផលចំនួន ២.២០៨គ្រួសារ មានសមាជិក ៩.៣០០នាក់។ **ទី៤**-ការងារជីកប្រឡាយរងអូរដូនពៅ និងសាងសង់សំណង់សិល្បការស្ថិតនៅឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ប្រឡាយរងអូរដូនពៅ ប្រវែង ៤.៣០០ម៉ែត្រ។ ក្រោយការងារបញ្ចប់លទ្ធផលស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ៦៧០ហ.ត ស្រូវប្រាំងចំនួន ១៥៨ហ.ត ដំណាំរួមផ្សំចំនួន ១០ហ.តនិងប្រជាជនទទួលផលចំនួន ៤៥០គ្រួសារ មានសមាជិក ១.៩៣៥នាក់។ ការដ្ឋាននេះសម្រេចបាន៧០% **ទី៥**-ការងារសាងសង់ទំនប់អាងទឹកប៉ាក់ស្លា និងសាងសង់សំណង់សិល្បការស្ថិតនៅក្នុងឃុំស្រែជាខាងជើង និងឃុំស្រែជាខាងត្បូង ស្រុកដងទង់ ខេត្តកំពត។ ទំនប់អាងទឹកប៉ាក់ស្លាប្រវែង ៤.៤០០ម៉ែត្រ។ ទំនប់នេះមានលទ្ធផលស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ៧៥៨ហ.ត ស្រូវប្រាំងចំនួន ១៩៥ហ.ត ដំណាំរួមផ្សំចំនួន ៤១០ ហ.ត និងអ្នកទទួលផលចំនួន ១.៩៦៨គ្រួសារ មានសមាជិក ៨.៤៨៩នាក់។ ការដ្ឋាននេះសម្រេចបាន ៦០%។ **ទី៦**-ការងារសាងសង់សំណង់ស្ទាក់ទឹកលើព្រែកមុខកំពូលស្ថិតនៅឃុំសំបូរមាសស្រុកមុខកំពូលខេត្តកណ្តាល។ សំណង់នេះមានលទ្ធភាពស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ២៨០ហ.ត ស្រូវប្រាំងចំនួន ៣០ហ.ត ដំណាំរួមផ្សំចំនួន ៤០ហ.តនិងអ្នកទទួលផល ២.៩៤១គ្រួសារ មានសមាជិក ១៤.៧១៥នាក់។ ការដ្ឋាននេះសម្រេចបាន ៧៥% **ទី៧**-ការងារជីកព្រែកផ្លាញ និង សាងសង់សំណង់សិល្បការស្ថិតនៅឃុំព្រែកឬស្សី ស្រុកល្ទាឯម ខេត្ត កណ្តាល ប្រវែង ៥.៧០០ម៉ែត្រ និងមានលទ្ធភាពស្រោចស្រពផ្ទៃដីស្រូវប្រាំងចំនួន ៥២០ហ.ត ដំណាំរួមផ្សំចំនួន ៥ហ.តនិងអ្នកទទួលផល ៨១៨គ្រួសារ មានសមាជិក ៣.៩៦៥នាក់។ការងារនេះសម្រេចបាន ៧០% **ទី៨**-ការងារសាងសង់ទំនប់ការពារទឹកប្រែទ្រៀកស្ថិតនៅឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង។ការសាងសង់ទំនប់ការពារទឹកប្រែទ្រៀកប្រវែង ៤.៦០០ម៉ែត្រ និងមានលទ្ធភាពស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ៩៩៣ហ.ត ដំណាំរួមផ្សំចំនួន ៦០ហ.តនិងអ្នកទទួល ផល៤៧៥គ្រួសារ មានសមាជិក ១.៧១១នាក់។ការងារនេះសម្រេច បាន ៦០% **ទី៩**-ការងារសាងសង់ទំនប់អាងទឹកត្រពាំងព្រៃ ជីកប្រឡាយ និងសាងសង់សំណង់សិល្បការស្ថិតនៅឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ។ ការសាងសង់ទំនប់អាងទឹកត្រពាំងព្រៃ ប្រវែង ៨៥០ម៉ែត្រ។ លទ្ធភាពស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ១៦៨ហ.ត ស្រូវប្រាំងចំនួន ៣៥ហ.ត ដំណាំរួមផ្សំចំនួន ២៦ហ.តនិងអ្នកទទួលផល ៥៥គ្រួសារ មានសមាជិក ៣៨៥នាក់។ ការងារនេះសម្រេចបាន ៧០%។ **ទី១០**-ការងារជីកព្រែកពន្លៃ និងសាងសង់សំណង់សិល្បការស្ថិតនៅឃុំបាបោងស្រុកពាមរក៍ខេត្តព្រៃវែង ប្រវែង ៣.៥៥០ម៉ែត្រ។ លទ្ធភាពស្រោចស្រពរបស់វាលើផ្ទៃដីស្រូវវស្សាចំនួន ៦១៧ហ.ត ស្រូវប្រាំងចំនួន ១.៨៧៨ហ.ត ដំណាំរួមផ្សំចំនួន ១០ហ.តនិងអ្នកទទួលផល ១.៧២១គ្រួសារ មានសមាជិក ៧.៥៣៦នាក់។ ការងារនេះសម្រេច បាន ៧០% **ទី១១**-ការងារសាងសង់ទំនប់សណ្តរឈើតោក និងសាងសង់ សំណង់បង្ហៀរ(ទ្វារ៥)ស្ថិតនៅឃុំសន្ទ្រៃ ស្រុកភ្នំក្រវាញ ខេត្តពោធ៏សាត់។ទំនប់នេះមានលទ្ធផលស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ២.០១៨ហ.ត ស្រូវប្រាំងចំនួន ១៨២ហ.ត ដំណាំរួមផ្សំចំនួន ២០ហ.តនិងអ្នកទទួល ផល ៦.០០១គ្រួសារ មានសមាជិក ២២.៩៦៩នាក់។ ការងារនេះ សម្រេចបាន ៧០% **ទី១២**-ការងារសាងសង់ទំនប់អាងទឹកកំពង់ចក ស្ថិតនៅឃុំកំពង់ចក ស្រុករំដួល ខេត្តស្វាយរៀង។ ការសាងសង់ទំនប់អាងទឹកកំពង់ចក ប្រវែង ១.៦៧០ម៉ែត្រ។ ទំនប់នេះមានលទ្ធភាព ស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ២៤៥ហ.ត ស្រូវប្រាំងចំនួន ៣០ហ.ត ដំណាំរួមផ្សំចំនួន ១៥ហ.តនិងអ្នកទទួលផល ៧៨៣ គ្រួសារ មាន សមាជិក ៣.៣០៩នាក់ ។ការងារសម្រេចបាន ៧៥%។ **ទី១៣**-ការងារសាងសង់ទំនប់សណ្តរអាងទឹកជីច្រាប និងសាងសង់សំណង់សិល្បការស្ថិតនៅឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ។ការសាងសង់ទំនប់សណ្តរអាងទឹកជីច្រាប មានប្រវែង ២.៧០០ម៉ែត្រនិងមានលទ្ធភាពស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ១.២៤៨ហ.ត ស្រូវប្រាំងចំនួន ៧១៦ហ.ត ដំណាំរួមផ្សំចំនួន ៩៩ហ.តនិងអ្នកទទួលផល ៧៤៨ គ្រួសារ មាន សមាជិក ៣.៤២៣នាក់។ការងារនេះសម្រេចបាន ៥៥% និង**ទី១៤**-ការងារសាងសង់សំណង់ ស្ទាក់ទឹកព្រែកជីកស្ថិតនៅឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ ការសាងសង់សំណង់ស្ទាក់ទឹកព្រែកជីក(ទ្វារ២) ចំនួនមួយកន្លែង និងមានលទ្ធភាពស្រោចស្រពផ្ទៃដីស្រូវវស្សាចំនួន ១២០ហ.ត ស្រូវប្រាំងចំនួន ៤៥ហ.ត ដំណាំចំការចំនួន ៨៨៧ហ.ត និងអ្នកទទួលផល ២.០១១គ្រួសារ មានសមាជិក ៩.២៩៦នាក់។ ការងារ នេះសម្រេចបាន ៧០%។

ខណៈនេះទោះបីជាកម្ពុជា កំពុងប្រឈមនឹងវិបត្តិបង្កដោយជំងឺកូវីដ-១៩ ក្តី ក៏បណ្តាការដ្ឋានទាំងនេះបាននិងកំពុងជំរុញដំណើរការដដែលទៅតាមផែនការគ្រោងទុក ។

ការដ្ឋានតាសុវណ្ណ ១ និងតាសុវណ្ណ ២ឃុំកំពង់ព្រា ស្រុកសង្កែ

ខេត្តស្វាយរៀង ស្ថិតនៅទិសអាគ្នេយ៍នៃព្រះ-រាជាណាចក្រកម្ពុជា។ បើយើងធ្វើដំណើរពីភ្នំពេញ ទៅខេត្តស្វាយរៀងមានចម្ងាយផ្លូវប្រវែង ១២៥ គ.ម. និងត្រូវធ្វើដំណើរតាមបណ្តោយផ្លូវជាតិ លេខ១ ដោយឆ្លងកាត់ខេត្តកណ្តាល និងខេត្ត ព្រៃវែង។ ខេត្តស្វាយរៀងមានព្រំប្រទល់អន្តរជាតិ ដ៏សំខាន់ជាប់នឹងច្រកព្រំដែនក្រុងបាវិតដែលមាន ចម្ងាយប្រមាណ៤៨គ.ម.ពីទីរួមខេត្តស្វាយរៀង។

យោងតាមឯកសារមួយចំនួនក៏ដូចជាសៀវ-ភៅឯកសារមហាបុរសខ្មែរបានបញ្ជាក់ថា៖ ខេត្ត ស្វាយរៀង បានបង្កើតឡើងដោយអាណានិគម-និយមបារាំង ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង រដ្ឋបាលខេត្ត និងងាយប្រមូលពន្ធពីប្រជារាស្ត្រ ខ្មែរ។ តែដោយការពិតនោះមុនសម័យបារាំងពុំទាន់ មានឈ្មោះថា ខេត្តស្វាយរៀងនៅឡើយទេ រហូត មកដល់អំឡុងឆ្នាំ១៩២២ ក្នុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិទើបបារាំងបានបង្រួមយកខេត្តស្វាយទាប ខេត្តរំដួល ខេត្តរមាសហែក និងមួយផ្នែកនៃខេត្ត រោងដំរីព្រមទាំងខេត្តបាត់មករួមបង្កើតចេញជា ខេត្តស្វាយរៀងជាប់ឈ្មោះរហូតមកដល់ បច្ចុប្បន្ន នេះ។ នៅក្នុងស.វ.ទី១៣ ក្នុងរាជព្រះបាទពញា យ៉ាត ខេត្តមួយចំនួនត្រូវបានបង្កើតឡើង។ លុះ ក្នុងស.វ.ទី១៤ ក៏ឃើញមានការរៀបចំបង្កើតខេត្ត មួយចំនួនបន្ថែមទៀតដូចជា៖ ខេត្តរំដួល ខេត្ត ស្វាយទាប ខេត្តរមាសហែក ដែលត្រូវបានផ្តាច់ ចេញពីខេត្តរោងដំរី នៅព្រៃនគរ ខេត្តបាត់ និង ខេត្តត្បូងឃ្មុំ។ ខេត្តស្វាយទាប និងខេត្តរំដួល ភាគខាងត្បូងលាតសន្ធឹងដល់ខេត្តទួលតាមោក និងខេត្តគោកសណ្តែកដែលបច្ចុប្បន្ននេះគឺជាខេត្ត ឡុងអានប្រទេសវៀតណាម ។ ខេត្តដែលបង្កើត ថ្មីទាំងបីត្រូវកំណត់បង់ពន្ធ និងប្រមូលពន្ធដាក់ ឃ្លាំងព្រះរាជទ្រព្យនៅខេត្តបាត់។ លុះដល់សម័យ បារាំងបានចាប់ ផ្តើមមកត្រួតត្រាប្រទេសកម្ពុជា ចាប់ពីចន្លោះឆ្នាំ១៨៦៣ ទៅដល់ឆ្នាំ១៩៥៣ បារាំងក៏បានរៀបចំរដ្ឋបាលខេត្ត និងបែងចែក តំបន់គ្រប់គ្រងសារជាថ្មី។ កាលនោះប៉ុស្តិ៍រដ្ឋបាល មួយនៅខេត្តរំដួលត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៨៩ ដែលមានវ៉ែស៊ីដង់បារាំងជាអ្នកគ្រប់គ្រង។ វ៉ែស៊ីដង់ ម្នាក់នេះមានសិទ្ធិគ្រប់គ្រងខេត្តពីរទៀតគឺ ខេត្ត ស្វាយទាបនិងខេត្តរមាសហែក។ មកដល់ឆ្នាំ១៩២០ ដល់ឆ្នាំ១៩២១ អគ្គទេសាភិបាលបារាំងប្រចាំ នៅឥណ្ឌូចិនក៏បានរៀបចំខេត្តខ្មែរមួយចំនួនសារ ជាថ្មីទៀត ។ ការរៀបចំនេះដោយពិនិត្យឃើញ ថា ខេត្តមួយចំនួនត្រូវប្តូរចេញឬលប់ឈ្មោះហើយ ត្រូវរៀបចំខេត្តថ្មីមួយចំនួនទៀត គឺតាំងពីប៉ុស្តិ៍រដ្ឋ បាលទៅជាខេត្តរីឯខេត្តចាស់មួយចំនួនត្រូវប្តូរទៅ ជាខណ្ឌ ឬស្រុកវិញ ទៅតាមស្ថានភាពរស់នៅ របស់ប្រជារាស្ត្រ។

គួរយល់ដឹងផងដែរថា អំឡុងពេលដែលបារាំង ត្រួតត្រាប្រទេសខ្មែរនោះ អគ្គទេសាភិបាលបារាំង ប្រចាំនៅទីក្រុងភ្នំពេញក៏បានរៀបចំឲ្យទេសាភិបាល

បារាំងដែលគ្រប់គ្រងនៅតាមប៉ុស្តិ៍និមួយៗ មាន សិទ្ធត្រួតត្រាលើខេត្តចំនួនពីរឬបីទៅតាមស្ថានភាព ជាក់ស្តែង។ ដោយឡែកប៉ុស្តិ៍រដ្ឋបាលនៅខេត្ត ស្វាយរៀងវិញ ដែលបានបង្កើតនៅឆ្នាំ១៨៨៩ សម្រាប់ធ្វើជាទីតាំងធំហើយខេត្តរំដួល ខេត្តស្វាយ-ទាប និងខេត្តរមាសហែកត្រូវឡើងមកបង់ពន្ធជូន បារាំង។

ក្រោយមក មុននឹងមានគម្រោងបង្រួមខេត្ត និងបង្កើតខេត្តថ្មីភូឈួយរដ្ឋបាលខេត្តស្វាយរៀង បានរៀបចំរបាយការណ៍ មួយចំនួនជូនដល់អគ្គ-ទេសាភិបាលបារាំង និងថ្វាយដល់ព្រះរាជាខ្មែរ ដើម្បីរៀបចំបង្កើតខេត្តថ្មី។ តាមរបាយការណ៍បាន បញ្ជាក់ថា ខេត្តរំដួល ខេត្តស្វាយទាប និងខេត្ត រមាសហែកមានប្រជាជនប្រមាណត្រឹមតែជាង ៥ម៉ឺននាក់ប៉ុណ្ណោះ។ ដោយយោងតាមចំនួន ប្រជាជនដ៏តិចតួចនោះ ហើយទើបរដ្ឋការបារាំង ខ្មែរជំនាន់នោះសម្រេចឯកភាពគ្នាបង្រួមខេត្តទាំង បីខាងលើដោយបង្កើតឲ្យទៅជាខេត្តមួយ ដើម្បី ងាយស្រួលក្នុងការគ្រប់គ្រង។ ប៉ុន្តែមុនពេល សម្រេចដាក់ឈ្មោះខេត្តថ្មីនោះរដ្ឋបាលបារាំងបាន កោះហៅចៅហ្វាយស្រុក និងចៅហ្វាយខេត្តទាំង បីមកប្រជុំរកឈ្មោះថ្មីសម្រាប់ដាក់ឲ្យខេត្តនេះ ។ ពេលនោះក្នុងបណ្តាមេឃុំទាំងនោះមានលោកមេឃុំ ស្វាយជ្រុំឈ្មោះថា តាព្រំបានមានយោបល់ថា នៅក្នុងភូមិសាស្ត្រទាំងបីខេត្តនេះគឺមានពាក្យផ្តើម ដោយឈ្មោះស្វាយច្រើនណាស់មាន ឈ្មោះភូមិ ឃុំនិងឈ្មោះវត្តជាដើម។ លោកវ៉ែស៊ីដង់ក៏ឲ្យ លោកមេឃុំរៀបរាប់ឈ្មោះភូមិឃុំដែលផ្តើមដោយ ពាក្យស្វាយមានចំនួន៣៨ ដូចជា៖ ភូមិស្វាយ, ភូមិស្វាយតាក្ត, ភូមិស្វាយធំ, ស្វាយក្ងោក, ស្វាយ ផ្អែម, ស្វាយព្រហូត, ស្វាយជ្រុំ, ស្វាយអង្គរ, ស្វាយ ដូនអ៊ី, ស្វាយយារ, ស្វាយគយ, ស្វាយក្អែរ, ស្វាយ ជម្រៅ, ស្វាយរំពា, ស្វាយចេក, ស្វាយកណ្តាល, ស្វាយតាយាន, ស្វាយគុយ, ស្វាយអាណាត, ស្វាយតឿ, ស្វាយចៅ,ស្វាយរូង, ស្វាយរលំ, ស្វាយជុំ, ស្វាយទន្ទឹម, ស្វាយបុទ្ទម, ត្រពាំងស្វាយ, អង្គស្វាយ, អង្គរក្សស្វាយនិងភូមិបូសស្វាយ។ រីង ស្រុកផ្សេងទៀតក៏មានឈ្មោះស្វាយជាច្រើនផង ដែរ។ ចំណែកវត្តមានពាក្យផ្តើមដោយឈ្មោះ ស្វាយមានចំនួន១៥ និងទួលបុរាណវត្តចាស់ចំនួន ១៦មានដូចជា៖ វត្តស្វាយជ្រុំ, វត្តស្វាយផ្អែម, វត្តស្វាយអង្គរ, វត្តស្វាយព្រហូត, វត្តស្វាយធំ, វត្តស្វាយយារ, វត្តស្វាយរំពា, វត្តស្វាយកណ្តាល, វត្តស្វាយតាយាន, វត្តស្វាយបុទ្ទម, វត្តស្វាយទន្ទឹម, វត្តស្វាយមានពីរវត្ត និងវត្តស្វាយជុំ។ រីងទួល បុរាណមានដូចជា៖ ទួលស្វាយរាំង, ទួលស្វាយ ព្រំគ្រង, ទួលស្វាយអណ្តើក, ទួលស្វាយកន្ត្រៃ ។

យោងតាមកិច្ចប្រជុំពិភាក្សានិងការសាកសួរ ពីប្រជារាស្ត្រអ្នកជំនាញបារាំងអមលោកវ៉ែស៊ីដង់ ក៏បានវាយតម្លៃថាឈ្មោះ ដែលគួរដាក់ឲ្យខេត្តថ្មី នោះគឺ **«ខេត្តស្វាយរៀង»** ។ បើយោងតាមប្រវត្តិ-សាស្ត្រស្របពេលនោះដែរ ខេត្តមួយចំនួននៃនគរ ខ្មែរនាសម័យនោះក៏បានប្តូរឈ្មោះផងដែរ ដូចជា ខេត្តបាត់ប្តូរទៅជាខេត្តព្រៃវែង ខេត្តទ្រាំងប្តូរទៅ ជាខេត្តតាកែវ ខេត្តក្រគរប្តូរទៅជាខេត្តពោធិសាត់ និងខេត្តត្បូងឃ្មុំប្តូរទៅជាខេត្តកំពង់ចាម។ ក្រោយពី បានសិក្សាប្រជាសាស្ត្រនិងភូមិសាស្ត្រ និងគូស ផែនទីដោយក្រុមលេខាគណិតបារាំងរួចមកអគ្គ-ទេសាភិបាលបារាំងប្រចាំទីក្រុងភ្នំពេញ និងអម ដោយសេនាបតីរាជការខ្មែរជាន់ខ្ពស់មានក្រសួង មហាផ្ទៃក្រសួងពន្ធដារព្រមទាំងឧកញ៉ាសេនាបតី តំណាងឲ្យព្រះមហា ក្សត្រខ្មែរក្នុងរាជព្រះបាទ ស៊ីសុវត្ថិបានបើកកិច្ចប្រជុំ និងបានឯកភាពលើ ការបង្កើតខេត្តថ្មីនេះនៅថ្ងៃទី២ ខែមេសា ឆ្នាំ ១៩២២។ ព្រះអង្គបានចេញរាជបញ្ជតលេខ៤៩ ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ១៩២២ និងត្រាស់បង្គាប់ ឲ្យបង្កើតខេត្តស្វាយរៀងនេះ ជាផ្លូវការដែលជាប់ ជារហូតមកដល់សម័យបច្ចុប្បន្ននេះ។

